■ ពលរដ្ឋកម្ពុជាគួរនាំគ្នាលើកតម្កើងចំណុចល្អរបស់តំបន់ខ្លួនរស់នៅ <ទំព័រ ៣
■ គ្រីស្តបរិស័ទអ្នកលឿងធ្វើបូជនីយសក់កន្លែងមរណបុគ្គល <ទំព័រ ១៣
■ លោកអភិបាលអូលីវីយេ លើកពីតំរូវចំណុចរបស់សន្តប្រាង់ស៊ីស្កូអាស៊ីស៊ី <ទំព័រ ១៥

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១៣

# អ្នកនាំសារ
# the messenger

ខែ កញ្ញា - តុលា | ឆ្នាំ ២០២៣ | លេខទី ១៦០
www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/ Oct-Nov, 2023 | #160



## គ្រីស្តបរិស័ទសាទរទទួល
# បូជាចារ្យថ្មីបីរូប

គ្រីស្តបរិស័ទជិត៣០០០នាក់បានមកចូលរួមពិធីតែងតាំងលោកបូជាចារ្យភូមិភាគចំនួនបីអង្គ គឺលោកយ៉ូហានបាទីស្ត វី សំណាង លោកប៉ូល វិនកាន់ និងលោកអន់តូនី ថៃ រតនៈ(ប៊ុនលី) នៅមជ្ឈមណ្ឌលភូមិភាគភ្នំពេញ ក្នុងរាជធានីភ្នំពេញ

រឿងពេញទំព័រទី ១៤

# ពលរដ្ឋកម្ពុជាគួរនាំគ្នាលើកតម្កើងចំណុចល្អរបស់តំបន់ខ្លួនរស់នៅ

ប្រទេសកម្ពុជាតូចមែន តែសម្បូរដោយធនធានជាច្រើនដែលពលរដ្ឋគ្រប់រូបតែងតែមើលឃើញនិងកោតសរសើរ ក្នុងនោះរួមមាន តំបន់ទេសចរណ៍ជាតិ ធម្មជាតិសំបូរបែប អាកាសធាតុសមស្រប ប្រជាពលរដ្ឋរួសរាយនិងរាក់ទាក់ ហើយក៏មានវប្បធម៌និងអរិយធម៌ល្អផូរផង់តាំងពីដើមរៀងមក។ តើយើងម្នាក់ក្នុងនាមជាកូនខ្មែរ អាចនាំគ្នាលើកស្ទួយចំណុចល្អៗរបស់យើងឲ្យប្រទេសជាតិនានាបានស្គាល់ខ្មែរកាន់តែច្បាស់ជាងនេះដែរទេ?

នៅក្នុងដែនដីដែលមានទំហំ១៨១ ០៣៥ គីឡូម៉ែត្រការ៉េ កម្ពុជាបែងចែកជារដ្ឋបាលខេត្តនិងរាជធានីសរុប២៥ ហើយនៅក្នុងទីតាំងទាំងអស់នោះ មានចំណុចល្អៗជាច្រើនដើម្បីយកមកបង្ហាញ ជាពិសេសគឺវប្បធម៌ និងប្រពៃណីដែលបង្ហាញពីអរិយធម៌ទំនើបរបស់ដូនតាដែលបន្សល់ទុកសម្រាប់យើងម្នាក់ៗ មានដូចជាម្ហូបអាហារ ទីតាំងភូមិសាស្ត្រនិងប្រវត្តិសាស្ត្រ វប្បធម៌សាសនា របៀបរស់នៅប្រចាំថ្ងៃ សិល្បៈ ការកែច្នៃផលិតផលផ្សេងធនធានធម្មជាតិ សត្វព្រៃ ស្មៅញញឹម និងក្តីសង្ឃឹមជាដើម។

ដោយសារតែសង្គ្រាម ប្រទេសយើងបាននៅស្ងាត់ឈឹងមួយរយៈពេលខ្លី ហើយអ្វីៗបានធ្លាក់ចុះ ដែលឲ្យគេស្គាល់និងដឹងអំពីប្រទេសដ៏តូចមួយនេះ ត្រឹមតែទុក្ខវេទនា និងការឈឺចាប់ គ្រាប់មីននិងសង្គ្រាមប៉ុណ្ណោះ។ គេមិនបានដឹងអំពីសម្បត្តិដ៏ល្អត្រកាលរបស់យើងដែលកំពុងរស់នៅលើដែនដីសុវណ្ណភូមិមួយនេះឡើយ។ ដូច្នេះ ដើម្បីឲ្យពិភពលោកបានដឹងថា ពេលនេះកម្ពុជាជាអ្វី ហើយមានលក្ខណៈបែបណានោះ មានតែយើងដែលជាកូនចៅជំនាន់បច្ចុប្បន្ននេះ គាស់កកាយចេញមក និងរំលេចនូវអ្វីដែលខ្មែរមាន។

ក្នុងពេលនេះ ការផ្សព្វផ្សាយមានច្រើនបែបផែនណាស់ យើងអាចធ្វើតាមបណ្តាញសង្គមដែលយើងកំពុងប្រើប្រាស់ កំពុងតែពេញនិយម មានតាំងពីហ្វេសបុក តិកតក់ អ៊ីនស្តាក្រាម ធ្វីតធ័រ តេឡេក្រាម យូធូប គឺអាចផ្សព្វផ្សាយបានទូលំទូលាយ និងងាយស្រួល ហើយបានទៅដល់មនុស្សរាប់លាននាក់ក្នុងពិភពលោក។

ការលើកតម្កើងពីប្រទេសខ្លួនឯង មិនមែនជារឿងអាក្រក់នោះទេ កុំឲ្យតែភ្លៀងពីសេចក្តីពិត ព្រោះការនិយាយសេចក្តីអាក្រក់និងខុសពីការពិតនាំឲ្យមានវិនាសកម្ម និងជាអំពើបាប។ ព្រះជាម្ចាស់មានព្រះបន្ទូលថា «អ្នកណានាំគេឲ្យប្រព្រឹត្តអំពើបាប អ្នកនោះត្រូវវេទនាហើយ» (លក១៧,១)។

ចំណុចល្អៗជាច្រើនដែលបរទេសចង់ស្គាល់ពីកម្ពុជានោះមានច្រើនណាស់ ដែលនាំឲ្យគេចង់ឃើញ គេចង់មកលេង គេចង់ភ្លក់រសជាតិ ដូច្នេះគួរតែចាប់ផ្តើមនាំគ្នានិយាយចាប់ពីពេលនេះ។ តាមតួលេខរបស់វេបសាយDataReportal បានបង្ហាញនៅថ្ងៃទី១៣ វិច្ឆិកា ២០២៣នេះឲ្យដឹងថា ក្នុងដើមឆ្នាំ២០២៣ អ្នកប្រើប្រាស់អ៊ីនធឺណេតនៅកម្ពុជាមានចំនួន១១,៣៧លាននាក់។ ហើយកម្ពុជាក៏មានអ្នកប្រើប្រាស់បណ្តាញសង្គមមានចំនួន១០,៩៥លាន គឺស្មើនឹង៦៥%នៃចំនួនប្រជាជនសរុបជាង១៦លាននាក់។ ទិន្នន័យនេះ បញ្ជាក់ថា យើងម្នាក់ៗអាចមានលទ្ធភាពឆ្ពោះទៅមុខ ដើម្បីលាតត្រដាងចក្ខុវិស័យនៃប្រទេសកម្ពុជាលើវប្បធម៌ អរិយធម៌ សាសនា និងភាពសំបូរបែបរបស់កម្ពុជាឲ្យសាសន៍ដទៃបានស្គាល់និងដឹងយ៉ាងទូលំទូលាយ។

ទង្វើរបស់យើងដែលនឹងធ្វើនៅពេលនេះ គឺទស្សនវិស័យមួយ ជួយឲ្យសេដ្ឋកិច្ចបានរីកចម្រើនផងដែរ បើកាលណាមានភ្ញៀវទេសចរណ៍ច្រើន យើងដែលជាម្ចាស់ផ្ទះនឹងអាចរកចំណូលបានពីវិស័យនេះ។ ដូច្នេះ កុំខ្លាចនឹងប្រកាសផ្សាយពីភាពបវររបស់ប្រទេសនិងតំបន់ដែលយើងរស់នៅ។ យើងទាំងអស់គ្នាគួរតែរួមគ្នាចូលរួម និង ផ្តួចផ្តើមអោយមានយុទ្ធនាការនេះឡើង៕









*រូបភាព៖ ក្រសួងទេសចរណ៍*

Formation, Dailouge, Cooperation
**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

**ចាងហ្វាង : លោក លី សុវណ្ណា**
សេចក្តីប្រកាសលេខ៖ លេខចុះបញ្ជី២០២២៖ ១២៧៩|២២ធត.ប្រ
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
**Contact: (855) 17 726 060**
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# កម្ពុជាដាក់បញ្ចូលការចាក់វ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូន ក្នុងកាលវិភាគផ្តល់ថ្នាំបង្ការជាប្រចាំ








*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងសុខាភិបាលបានប្រកាសដាក់បញ្ចូលវ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូន (HPV) ដែលត្រូវចាក់តែមួយដូស ដល់កុមារីអាយុ ៩ ឆ្នាំ ទៅក្នុងកាលវិភាគផ្តល់ថ្នាំបង្ការជាតិ ដោយមិនគិតថ្លៃ នៅទូទាំងប្រទេស តាមរយៈការចុះផ្តល់សេវា ជាទៀងទាត់នៅតាមសាលារៀននិងសហគមន៍ និងការផ្តល់សេវាជាប្រចាំនៅ មណ្ឌលសុខភាព ។

នៅកម្ពុជា ជំងឺមហារីកមាត់ស្បូនជាជំងឺមហារីកដែលកើតមានញឹកញាប់ជាងគេលំដាប់ទីពីរ និងជាមូលហេតុចម្បងទីបីនៃមរណភាពដែលបណ្តាលមកពីជំងឺមហារីក ក្នុងចំណោមស្ត្រីគ្រប់វ័យ ដោយមានការប៉ាន់ប្រមាណថាមានករណីថ្មីៗប្រមាណ ១ ១៣៥ ករណី និងស្លាប់ ៦៤៣ ករណីជារៀងរាល់ឆ្នាំ។

ភស្តុតាងថ្មីៗពីអង្គការសុខភាពពិភពលោកបង្ហាញថា ការចាក់វ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូនមួយដូស មានប្រសិទ្ធភាពកាត់បន្ថយការបង្ករោគដោយ HPV និងបង្ការ ជំងឺមហារីកមាត់ស្បូនពី ៨០ ទៅ ៩០ ភាគរយ។

លោក ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានលើកទឹកចិត្តដល់មន្ត្រីសុខាភិបាលនិងដៃគូទាំងអស់ឱ្យធ្វើការរួមគ្នា ដើម្បីការពារកុមារីគ្រប់រូបនៅកម្ពុជា។

លោកមានប្រសាសន៍ថា ៖ «ជំងឺមហារីកមាត់ស្បូន គឺជាអាទិភាពផ្នែកសុខភាពសាធារណៈរបស់កម្ពុជា។ យើងកំពុងពន្លឿនកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើង ដើម្បីលុបបំបាត់ជំងឺដ៏សាហាវដែលអាចផ្តាច់ ជីវិតនេះ តាមរយៈការបញ្ចូលវ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូនទៅក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ»។




លោក ឈាង រ៉ា បានបន្តថា ៖ «យើងនឹងធានាថាកុមារីអាយុ ៩ ឆ្នាំគ្រប់រូប អាចទទួលបានវ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូនចំនួន ១ ដូស ដោយមិនគិតថ្លៃចាប់ពីថ្ងៃនេះតទៅ ព្រមទាំងគ្រោងនឹងផ្តល់វ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូននេះដល់កុមារីអាយុលើសពី ៩ ឆ្នាំ តាមរយៈយុទ្ធនាការមួយដែលនឹងត្រូវរៀបចំឡើងក្នុងឆ្នាំ ២០២៥ ខាងមុខនេះ»។

សូមរម្លឹកថា ពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៨ ក្រសួងសុខាភិបាលបានអនុវត្តគម្រោងសាកល្បងផ្តល់ថ្នាំបង្ការជំងឺមហារីកមាត់ស្បូន ដល់កុមារីអាយុ ៩ ឆ្នាំ ក្នុងស្រុកចំនួន ១០ នៃខេត្តចំនួន ២ គឺខេត្តសៀមរាប និងស្វាយរៀង ប្រកបដោយជោគជ័យ។

គម្រោងនេះសម្រេចបានការគ្របដណ្តប់ ៩៦ ភាគរយ ដែលនេះបង្ហាញថាការទទួលយកវ៉ាក់សាំងរបស់សហគមន៍ មានកម្រិត ខ្ពស់ និងបង្ហាញ ពីសមត្ថភាព និងការត្រៀមខ្លួនរួចជាស្រេចរបស់កម្ពុជា ក្នុងការផ្តល់ថ្នាំបង្ការនេះ នៅទូទាំងប្រទេស។ បច្ចុប្បន្ន កម្ពុជាចូលរួមជាមួយប្រទេសចំនួន ១៣៦ នៅទូទាំងពិភពលោក ក្នុងការបញ្ចូលវ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូនទៅក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

អ្នកស្រី នួន វង្ធា អាយុ៤៣ឆ្នាំ ដែលបាននាំកូនស្រីទៅទទួលវ៉ាក់សាំងការពារមហារីកមាត់ស្បូន កាលពីដើមខែតុលា បានប្រាប់ថា អ្នកស្រីសប្បាយរីករាយដែលក្រសួងសុខាភិបាលបានបង្កើតនូវយុទ្ធនាការចាក់វ៉ាក់សាំងនេះ ដែលធ្វើឱ្យអ្នកស្រីមានទំនុកចិត្តច្រើនជាងមុន។

អ្នកស្រី បានប្រាប់ថា ពីមុនអ្នកស្រីមិនសូវច្បាស់ក្នុងចិត្តទេថាក្មេងស្រីដែលអាយុទើបតែ ៩ឆ្នាំអាចចាក់វ៉ាក់សាំងនេះបាន ហើយអ្នកស្រីតែងគិតថាទាល់តែកូនអាយុលើស១០ឆ្នាំ ឬដល់ ២០ឆ្នាំ ចាំនាំកូនទៅចាក់វ៉ាក់សាំងការពារមហារីកមាត់ស្បូននេះ។

អ្នកម្តាយរូបនេះ បានបញ្ជាក់ថា ៖ «ខ្ញុំនាំកូនទៅចាក់វ៉ាក់សាំងនៅមណ្ឌលសុខភាពតែម្តង ដើម្បីប្រាកដថាវាពិតជាមានសុវត្ថិភាពដល់សុខភាពកូនខ្ញុំ។ ជំងឺមហារីកកើតមានច្រើនណាស់សម័យនេះ មិនថាតែមហារីកមាត់ស្បូនទេ គឺមានមហារីកច្រើនមុខផ្សេងទៀត ដែលអ្នកកើតខ្លួនឯងមិនដឹងខ្លួនមុនឡើង»។

អ្នកស្រី នួន វង្ធា បន្តថា ការការពារមុនដោយការចាក់វ៉ាក់សាំងនេះគឺជាការល្អប្រសើរ ជាងកើតជំងឺនេះហើយបានទៅព្យាបាលដែលពេលខ្លះវាហួសពេល ឬរីករាលដាលធ្ងន់ធ្ងរដែលលែងអាចជួយសង្គ្រោះបាន។

លោក Will Parks តំណាងយូនីសេហ្វប្រចាំនៅកម្ពុជា លើកឡើងថា ការដាក់បញ្ចូលវ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូននៅកម្ពុជាជាផ្នែកមួយនៃការថែទាំសុខភាពបឋម។ លោកមានប្រសាសន៍ថា ៖ «យើងត្រូវធានាយ៉ាងណាឱ្យកុមារីដែលបានបំពេញតាមគ្រប់លក្ខខណ្ឌទាំងអស់ ជាពិសេសកុមារីរស់នៅតាមសហគមន៍ដែលមានហានិភ័យខ្ពស់ សហគមន៍ក្រីក្រនៃតំបន់ប្រជុំជន សហគមន៍ជនបទដាច់ស្រយាល ក៏ដូចជាជនជាតិភាគតិច និងអ្នកចំណាកស្រុក»។

លោកថា យូនីសេហ្វប្តេជ្ញាផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលុបបំបាត់ជំងឺមហារីកមាត់ស្បូន និងលើកកម្ពស់សុខភាពរបស់ប្រជាជនគ្រប់រូប។

ចំណែលោក Pascal Ringwald តំណាងស្តីទីរបស់អង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជាលើកឡើងដែរថា វ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូន គឺជាយុទ្ធសាស្ត្របង្ការបឋមមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅលុបបំបាត់ជំងឺមហារីកមាត់ស្បូន។

វ៉ាក់សាំងនេះមានសុវត្ថិភាព និងជាវិធានការដែលមានប្រសិទ្ធភាពខ្ពស់បំផុតសម្រាប់បង្ការជំងឺមហារីកមាត់ស្បូន។ ការសម្រេចបាននូវការគ្របដណ្តប់ជាង ៨០% នៃការចាក់ថ្នាំបង្ការជំងឺមហារីកមាត់ស្បូន ១ ដូស នឹងផ្តល់ប្រយោជន៍ដល់ប្រជាជន គ្រួសារ និងសហគមន៍កាន់តែច្រើននៅក្នុងបណ្តាទសវត្សរ៍ខាងមុខនេះ។

នាយកប្រចាំប្រទេសរបស់អង្គការ CHAI កម្ពុជា លោកស្រី Soleine Scotney ក៏បានសំដែងនូវការកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់ ក្រសួងសុខាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងអនាគតកុមារីកម្ពុជា។ លោកស្រីថា ការបន្តផ្តល់អាទិភាពដល់ថ្នាំបង្ការថ្មីៗដែលមានប្រសិទ្ធភាព ដូចជាថ្នាំបង្ការជំងឺមហារីកមាត់ស្បូននេះជាដើម គឺជាសក្ខីភាពដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រសួងសុខាភិបាលក្នុងការការពារសុខភាពរបស់ប្រជាជនកម្ពុជា។

រីឯលោក Thabani Maphosa នាយកគ្រប់គ្រងកម្មវិធីប្រចាំប្រទេសរបស់ Gavi លើកឡើងថា ការធ្វើសកម្មភាពរួមគ្នាជាបន្ទាន់ ឆ្ពោះទៅពង្រីកការផ្តល់វ៉ាក់សាំងនេះទៅគ្រប់សហគមន៍ទាំងអស់មានសារៈសំខាន់ជាសារវន្ត ដើម្បីធានាថាពុំមានកុមារីណាម្នាក់ត្រូវបានទុកចោលនោះឡើយ៕

# គណបក្សប្រជាជនកម្ពុជា និងគណបក្សនយោបាយ ២៧ទៀត ចុះកិច្ចព្រមព្រៀងចងសម្ព័ន្ធភាពជាផ្លូវការ

*អត្ថបទ៖ អមរិទ្ធ ដានុត*



គណបក្សប្រជាជនកម្ពុជា និងគណបក្សនយោបាយចំនួន២៧ ផ្សេងទៀត បានសម្រេចចុះកិច្ចព្រមព្រៀងចងសម្ព័ន្ធភាពជាផ្លូវការ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុនសែនប្រធានគណបក្សប្រជាជនកម្ពុជា និងថ្នាក់ដឹកនាំនៃគណបក្សទាំង២៧ផងដែរ។

សម្តេចតេជោ ហ៊ុន សែន បានលើកឡើងនាពិធីនោះថា ការចងសម្ព័ន្ធភាពរវាងបក្សនយោបាយទាំង២៨ មិនមែនជាបញ្ហាកញ្ជក់កណ្តៀត ហើយទោះបីជាគណបក្សប្រជាជនមានធនធានមនុស្ស និងហិរញ្ញវត្ថុច្រើន តែមិនបានមើលស្រាលបក្សដទៃនោះឡើយ តែបានចាត់ទុកជាដៃគូស្មើភាពស្មើសិទ្ធិគ្នា។

សម្តេចបានថ្លែងថា ៖ «ការចុះកិច្ចព្រមព្រៀងចងសម្ព័ន្ធភាពគ្នានេះ បង្ហាញនូវសាមគ្គីភាព និងការបើកទូលាយនៃគោលដៅរួមនៃការរក្សាសន្តិភាព និងការអភិវឌ្ឍរបស់កម្ពុជា។គោលការណ៍រួមសំខាន់ទាំងឡាយគឺត្រូវបានឯកភាពគ្នាដោយបានដាក់ចូលក្នុងកិច្ចសហប្រតិបត្តិការរបស់យើង មិនមែនជាបញ្ហាឆក់កណ្តៀតដូចសម្ព័ន្ធភាពខ្លះសំដៅដោះស្រាយបញ្ហាចំពោះមុខទៅលើការបោះឆ្នោតអសកលនៃព្រឹទ្ធសភាព ឬក្រុមប្រឹក្សាក្នុងខែកុម្ភៈ និងខែឧសភានោះទេ»។





ក្នុងពិធីចុះកិច្ចព្រមព្រៀងនោះដែរ ប្រធានគណបក្សប្រជាជនកម្ពុជា សម្តេចតេជោ ហ៊ុនសែន ក៏បានបញ្ជាក់ឱ្យដឹងដែរថា គណបក្សប្រជាជនមិនបានមើលទៅគណបក្សដទៃមានទម្រង់បែបណា មានធនធានបែបណា គឺជាប្រភេទគណបក្សមិនស្មើភាពជាដៃគូរបស់ខ្លួននោះទេ។

មួយវិញទៀត សម្តេចតេជោ ក៏បានបញ្ជាក់ផងដែរថា ៖ «យើងក៏ត្រូវនិយាយផងដែរពីការការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ។ តើហេតុអីយើងត្រូវនិយាយពីចំណុចនេះ? ឯកឧត្តមលោកជំទាវប្រហែលជាដឹងហើយថា ២-៣ឆ្នាំនេះមានអ្នកទាមទារឱ្យព្រះមហាក្សត្រចុះចេញពីរាជបល្ល័ង្គ តើនោះគឺជាអ្វី?»

សម្តេចបន្តថា៖«ក្នុងរដ្ឋធម្មនុញ្ញរបស់យើងមានកឋាខណ្ឌមួយបានចែងថារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងរបបរាជាធិបតេយ្យអាស្រ័យពហុបក្ស មិនអាចកែប្រែបានឡើយ។ សូម្បីតែរដ្ឋសភាទោះបីថាសម្លេងប៉ុន្មានក៏ដោយក៏មិនអាចកែប្រែចំណុច២នេះបានដែរ។ ដូចនេះ គណបក្សទាំង២៨ និងអាចមានគណបក្សផ្សេងទៀតមកចូលរួមបន្ថែមទៀត ត្រូវតែប្តេជ្ញាការពារឱ្យបាននូវរបបរាជាធិបត្យេអាស្រ័យរដ្ឋធម្មនុញ្ញ»។

លោក ម៉ង សូណង់ដូ ប្រធានគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ បានថ្លែងថា លោកមានមោទនភាពដែលបានចូលរួមក្នុងការចងសម្ព័ន្ធភាពនេះ ជាអ្វីដែលលោកអាចធ្វើបាន ជាពិសេសជោគជ័យនៃការរីកចម្រើន និងការបង្រួបបង្រួមគ្នា។

លោកបានថ្លែងថា៖«ចំពោះគណបក្សផ្សេងៗទៀតគឺជាសិទ្ធិរបស់គណបក្សផ្សេងៗ តែខ្ញុំគិតថាបើយើងមិនបានចូលរួមជាមួយគ្នា យើងក៏មិនបានស្គាល់ពួកគាត់ដែរ។ បើយើងចង់ស្គាល់សេះថាតើសេះនោះផ្ញើលយ៉ាងណា ឬសេះនោះយ៉ាងម៉េច គឺយើងត្រូវជិះលើសេះនោះ ទើបដឹងច្បាស់»។

ចំណែក លោក អ៊ិត សារម្យ ប្រធានគណបក្សបំណងពលរដ្ឋ បានលើកឡើងដែរថា ការចុះហត្ថលេខានេះ គឺឈរលើគោលការណ៍ និងដំណើរវិវឌ្ឍមួយនៃស្ថានភាពសេរីពហុបក្សនៅក្នុងប្រទេសកម្ពុជា ស្ថិតនៅក្នុងវ័យចំណាស់ បន្ទាប់ពីមានការឆ្លងកាត់នូវសង្គ្រាម និងការយល់ដឹងរបស់គណបក្សនយោបាយ និងប្រជាពលរដ្ឋ។

លោក ថា ៖ «យើងយល់ឃើញថា ការចងសម្ព័ន្ធភាពនេះជាដំណើរល្អនៃអ្នកនយោបាយ ព្រោះការធ្វើនយោបាយត្រូវប្រជែងគ្នាលើទស្សនៈ គោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្ស ហើយការចងសម្ព័ន្ធភាព យើងមិនស្ថិតនៅក្រោមឥទ្ធិពលរបស់គណបក្សណាមួយនោះទេ»។

លោក យង់ ពៅ អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា បានលើកឡើងថា និន្នាការទូទៅនៅក្នុងសង្គមប្រជាធិបតេយ្យ គណបក្សដែលមាននិន្នាការប្រហាក់ប្រហែលគ្នា ស្របគ្នា អាចចងសម្ព័ន្ធភាពជាមួយគ្នាបាន។

លោកបានថ្លែងថា ៖ «គណបក្សចំនួន២៨ បានចុះកិច្ចព្រមព្រៀងចងសម្ព័ន្ធភាពជាមួយគ្នា ដែលនេះជាកិច្ចព្រមព្រៀងមួយដែលគណបក្សទាំងអស់នោះមាននិន្នាការ ឬគោលដៅប្រហាក់ប្រហែលគ្នា។ ចឹង គេអាចចុះចងសម្ព័ន្ធគ្នាដើម្បីប្រមូលផ្តុំទស្សនៈ គំនិតក្នុងការបង្កើតគោលនយោបាយរួមជាមួយគ្នាណាមួយ»។

គណបក្សនយោបាយទាំង ២៨ ដែលបានចុះហត្ថលេខាចងសម្ព័ន្ធភាពគ្នារួមមាន៖ គណបក្សប្រជាជនកម្ពុជា, គណបក្សខ្មែររួបរួមជាតិ, គណបក្សពន្លឺថ្មី, គណបក្សសញ្ជាតិកម្ពុជា, គណបក្សខ្មែរក្រោក, គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, គណបក្សរស្មីខេមរា, គណបក្សខ្មែរសាធារណរដ្ឋ, គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច, គណបក្សយុវជនកម្ពុជា។

គណបក្សធម្មាធិបតេយ្យ, គណបក្សជនជាតិប្រជាធិបតេយ្យកម្ពុជា, គណបក្សខ្មែរតែមួយ, គណបក្សឯកភាពជាតិខ្មែរ, គណបក្សកម្លាំងប្រជាធិបតេយ្យ, គណបក្សកសិករ, គណបក្សស្ត្រីដើម្បីស្ត្រី, គណបក្សបំណងពលរដ្ឋ, គណបក្សខ្មែរអភិរក្ស, គណបក្សមហាសាមគ្គីជាតិខ្មែរ។

គណបក្សនគរប្រជាធិបតេយ្យ, គណបក្សអំណាចប្រជាពលរដ្ឋ, គណបក្សខ្មែរអង្គរ, គណបក្សកម្ពុជាសេរីឯករាជ្យប្រជាធិបតេយ្យ, គណបក្សម៉ូលីណាកា, គណបក្សចលនាប្រជាធិបតេយ្យ, គណបក្សអភិវឌ្ឍន៍កម្ពុជា និងគណបក្សមហានគរ។

យោងតាមខ្លឹមសារនៃកិច្ចព្រមព្រៀងចំនួន៨ចំណុចសំខាន់ៗ ដែលត្រូវបានមេដឹកគណបក្សនយោបាយទាំង២៨បានចុះហត្ថលេខាមានដូចជា ៖ ពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយគ្នាដោយស្មើភាព, ប្តេជ្ញាគោរព ប្រតិបត្តិ ការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្តេជ្ញាការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី, រួមសហការគ្នាដើម្បីទប់ស្កាត់ និងកំចាត់ចោលនូវនយោបាយជ្រុលនិយមចេញផុតពីកម្ពុជា។ ប្រឆាំងដាច់ខាតចំពោះឧបាយកល និងសកម្មភាពរបស់មជ្ឈដ្ឋានណាដែលព្យាយាមបំផ្លាញ ឯកភាពជាតិ បង្កអស្ថិរភាពក្នុងសង្គម, សហប្រតិបត្តិការល្អជាមួយគ្នា, គោរពអនុវត្តដោយស្មោះត្រង់ និងយកផលប្រយោជន៍ជាតិជាធំ និងកសាងពង្រឹងទំនាក់ទំនងសហប្រតិបត្តិការ ដើម្បីអនុវត្តឱ្យបានសម្រេចលទ្ធផលល្អនៃកិច្ចព្រមព្រៀងនេះ៕

# មជ្ឈមណ្ឌលធនធាន របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកឱ្យប្រើប្រាស់ជាផ្លូវការ

*អត្ថបទ៖ អមរិន្ទ ដានុត*






លោក វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រី ប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលទទួលបន្ទុកការអនុវត្តមុខងារសេសសល់របស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) និងមន្ត្រីនៃស្ថានទូតធំៗនៅកម្ពុជា បានប្រកាសសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលធនធានរបស់អ.វ.ត.ក. កាលពីចុងខែកញ្ញា ឆ្នាំ២០២៣ ។

មជ្ឈមណ្ឌលធនធាននេះ មានសមាសភាគសំខាន់ៗចំនួន៦ រួមមាន៖ បណ្ណាល័យ និងកន្លែងស្រាវជ្រាវ, គេហទំព័រថ្មីដែលកំពុងកែលម្អ និងធ្វើបច្ចុប្បន្នភាព, និហិតដ្ឋានបណ្ណសារ (Archives Repository), ប ន្ទប់ប្រើប្រាស់ពហុបំណងសម្រាប់ រៀបចំសិក្ខាសាលានិងតុលាការត្រាប់(Moot Court), បន្ទប់ពិគ្រោះយោបល់និងតាំងពិព័រណ៍ និងឧទ្យានសម្រាប់ការចងចាំ។

ក្នុងចំណោមសមាសភាគសំខាន់ៗទាំងនេះ បណ្ណាល័យ និងកន្លែងស្រាវជ្រាវ នៃមជ្ឈមណ្ឌលធនធានរបស់ អ.វ.ត.ក. ត្រូវបានបញ្ចប់ការសាងសង់ជាស្ថាពរកាលពីចុងខែឧសភា ឆ្នាំ២០២៣ និងទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន សិស្សនិស្សិត និងអ្នកស្រាវជ្រាវជាតិ-អន្តរជាតិ អំឡុងពេលដំណើរការសាកល្បងនាពេលកន្លងមក។



បន្ទាប់ពីពិធីសម្ពោធនាថ្ងៃនេះ បណ្ណាល័យ និងកន្លែងស្រាវជ្រាវនេះ នឹងត្រូវដាក់ក្រោមការគ្រប់គ្រងរួមគ្នាជាមួយមជ្ឈមណ្ឌលឯកសារច្បាប់ និងបើកបម្រើជាផ្លូវការ ចាប់ពីម៉ោង ១០ព្រឹក ដល់ម៉ោង ៨យប់ សម្រាប់ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ និងចាប់បើក ពីម៉ោង ១០ព្រឹក ដល់ម៉ោង ៦ល្ងាច សម្រាប់ថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក។

មជ្ឈមណ្ឌលធនធានរបស់ អ.វ.ត.ក. ក្នុងគោលបំណងថែរក្សា និងលើកកម្ពស់កេរដំណែល ពាក់ព័ន្ធនឹងបណ្ណសារនៃអង្គជំនុំគម្រះរបស់សាលាក្តីខ្មែរក្រហម ដើម្បីអនុញ្ញាតឱ្យសាធារណជនអាចចូលមើល និងសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់កម្ពុជាឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

លោក វង្សី វិស្សុត បានថ្លែងនាពិធីនោះថា ក្រោយពីបានបញ្ចប់ដំណើរការកាត់ក្តីប្រកបដោយជោគជ័យកាលពីចុងឆ្នាំ២០២២ និងដោយមានការគាំទ្រ និងទទួលស្គាល់ពីសហគមន៍អន្តរជាតិ អ.វ.ត.ក. បានបន្សល់ទុកនូវកេរដំណែលដ៏ល្អនៅក្នុងសង្គមកម្ពុជា។

លោកថា អ.វ.ត.ក. បានចូលរួមចំណែកពង្រឹងសមិទ្ធផលនៃសន្តិភាព ការផ្សះផ្សាជាតិ ការស្វែងរកការពិត ការពង្រឹងនីតិរដ្ឋ ការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ និងបញ្ចប់នូវវប្បធម៌និទណ្ឌភាព ចំពោះ ឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នង ដែលបានសម្លាប់រង្គាលនូវជីវិតប្រជាជនកម្ពុជាជាង ៣លាននាក់ ព្រមទាំងការលើកកម្ពស់ដល់ការចងចាំ និងការទប់ស្កាត់ការវិលត្រលប់មកវិញនៃរបបដ៏សាហាវយង់ឃ្នងនេះ។

លោក វង្សី វិស្សុត បានបញ្ជាក់ថា ៖ «ជាមួយនឹងធនធាននៃសំណុំរឿងដែលមានបទពិសោធន៍យ៉ាងច្រើន និងយុត្តិសាស្ត្រនានា ដែលទទួលបានពីដំណើរការកាត់សេចក្តីរបស់ អ.វ.ត.ក. កម្ពុជាក៏បានចែករំលែកទៅថ្នាក់តំបន់ និងអន្តរជាតិផងដែរ តាមរយៈការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍ពី អ.វ.ត.ក. ស្របតាមទិសដៅប្រែក្លាយកម្ពុជាពីប្រទេសធ្លាប់រៀនសូត្រពីគេ ទៅជាប្រទេសដែលគេមករៀនសូត្រវិញ ម្តង»។

លោកបន្តថា ៖ «ខ្ញុំគិតថា នេះជាជោគជ័យរួមរបស់រាជរដ្ឋាភិបាល, អង្គការសហប្រជាជាតិ, និងសហគមន៍ អន្តរជាតិ ដែលបានធ្វើឱ្យ

> ការបង្កើត មជ្ឈមណ្ឌលធនធាន អ.វ.ត.ក. គឺឆ្លើយតបទៅនឹងតម្រូវការក្នុងការអនុវត្តការងារផ្សព្វផ្សាយ និងអប់រំ ពាក់ព័ន្ធនឹងដំណើរការជំនុំជម្រះក្តី និងការងារគ្រប់គ្រងបណ្ណាសារឲ្យបានទូលំទូលាយដល់សាធារណជន និង តាមដានការអនុវត្តគម្រោងនានាដែលបានសម្រេចផ្តល់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៃរបបខ្មែរក្រហម

សាលាក្តីកូនកាត់នេះ ក្លាយជាតុលាការគំរូមួយ សម្រាប់ឱ្យប្រទេសនានាក្នុងតំបន់ និងសកលលោកសិក្សា និងយកធ្វើជាគំរូក្នុងការបង្កើតតុលាការវិនិច្ឆ័យទោសចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនាពេលអនាគត ក្នុងបុព្វហេតុស្វែងរកសន្តិភាពក្រោយសង្គ្រាម ឬជម្លោះរ៉ាំរ៉ៃផ្ទៃក្នុង»។

លោក ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. ក៏បានលើកឡើងដែរ អ.វ.ត.ក. មានមោទនភាពក្នុងការសម្ពោធមជ្ឈមណ្ឌលធនធាន និងប្រកាសផ្សព្វផ្សាយនូវវីដេអូខ្លីអប់រំ ជាស៊េរី។

លោកមានប្រាសាសន៍ថា ៖ «ការបង្កើត មជ្ឈមណ្ឌលធនធាន អ.វ.ត.ក. គឺឆ្លើយតបទៅនឹងតម្រូវការក្នុងការអនុវត្តការងារផ្សព្វផ្សាយ និងអប់រំ ពាក់ព័ន្ធនឹងដំណើរការជំនុំជម្រះក្តី និងការងារគ្រប់គ្រងបណ្ណាសារឲ្យបានទូលំទូលាយដល់សាធារណជន និង តាមដានការអនុវត្តគម្រោងនានាដែលបានសម្រេចផ្តល់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះនៃរបបខ្មែរក្រហម»។

សហប្រធាននៃក្រុមមិត្តអ.វ.ត.ក. រួមមាន លោក អ៊ូ អ៊ិណុ អាត់ស៊ូស៊ី ឯកអគ្គរដ្ឋទូតជប៉ុន, លោក Jacques PELLET ឯកអគ្គរដ្ឋទូតបារាំង, លោក Joseph SCHEUER អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប ឯកអគ្គរដ្ឋទូតសាធារណៈរដ្ឋកូរ៉េខាងត្បូង និងមិត្តភក្តិ រួមទាំងសមាជិកដៃគូអនុវត្តដទៃទៀត ក៏មានវត្តមាននៅក្នុងពិធីនេះផងដែរ។

ក្នុងឱកាសនៃពិធីនេះដែរ អ.វ.ត.ក. ក៏ប្រកាសដាក់ឲ្យដំណើរការផ្សព្វផ្សាយកម្មវិធីវីដេអូខ្លីអប់រំ ជាស៊េរី ដែលខ្លឹមសារនៃវីដេអូអប់រំនេះ គឺដកស្រង់ចេញពីឯកសារ កំណត់ត្រា និងបណ្តសារ ដែលរំលេចនូវប្រធានបទជាច្រើនទាក់ទងនឹងការជំនុំជម្រះក្តី និងការស៊ើបអង្កេតក្តីក្នុងរយៈពេល១៦ឆ្នាំ។ វីដេអូអប់រំខ្លីជាស៊េរី នឹងក្លាយជាផ្នែកសំខាន់មួយនៃសកម្មភាពអប់រំក្នុងគោលបំណងផ្សព្វផ្សាយអំពីការងាររបស់អ.វ.ត.ក. សម្រាប់យុវជនជំនាន់ក្រោយ។ វគ្គដំបូងនៃវីដេអូខ្លីអប់រំ ជាស៊េរី នេះ ត្រូវបានចេញផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងអស់របស់ អ.វ.ត.ក. រួមមាន ទំព័រហ្វេសប៊ុក យូធូប តេឡេក្រាម និងបណ្តាញសង្គមតិកតុក ផងដែរ។

សូមបញ្ជាក់ថា មជ្ឈមណ្ឌលធនធាន មានទីតាំងនៅក្នុងបរិវេណការិយាល័យថ្មីរបស់អ.វ.ត.ក. អគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី (ផ្លូវ១១០) សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ ដែលការចូលប្រើប្រាស់មជ្ឈមណ្ឌលធនធាននេះគឺ មិនគិតថ្លៃនោះទេ៕

# ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ឆ្នាំ២០២៤ ឡើងដល់ ២០៤ ដុល្លារក្នុង១ខែ





*អត្ថបទ៖ អមរិទ្ធ ដានុត*

រាជរដ្ឋាភិបាលសម្រេចតម្លើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូបសម្រាប់ ឆ្នាំ២០២៤ មានចំនួន២០៤ដុល្លារក្នុង១ខែ ដែលតួលេខនេះនឹងអនុវត្តចាប់ពីខែមករា ឆ្នាំក្រោយនេះ។

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងនារសៀលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ថា លោកបានសម្រេចបន្ថែម ២ដុល្លារ ក្នុង ១ខែ ទៅលើតួលេខ ២០២ដុល្លា ដែលជាលទ្ធផលបោះឆ្នោតរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាខាងលើ។ ដូច្នេះ ប្រាក់ឈ្នួលអប្បបរមាថ្មីសម្រាប់ឆ្នាំ២០២៤ គឺ ២០៤ដុល្លារ ក្នុង ១ខែ។

ទន្ទឹមនឹងការដំឡើងប្រាក់ឈ្នួលនេះ សម្តេចមហាបវរធិបតី ក៏បានប្រាប់ទៅដល់កម្មករនិយោជិត និងសាធារណជនថា សម្តេចនឹងបន្តជំរុញដល់ក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធពិនិត្យតាមដាន និងដាក់វិធានការបន្ថែម ដើម្បីពិនិត្យលទ្ធភាពកាត់បន្ថយបន្ទុកចំណាយរបស់បងប្អូនកម្មករនិយោជិត។

សម្តេចមហាបវរធិបតីថា ៖ «ទន្ទឹមនឹងនេះ ខ្ញុំនឹងដឹកនាំកិច្ចប្រជុំជាមួយវិស័យឯកជនមួយនៅខែវិច្ឆិកា ខាងមុខ ដើម្បីកែលម្អបរិយាកាសវិនិយោគ និងការធ្វើធុរកិច្ចនៅកម្ពុជា សំដៅបង្កើនភាពប្រកួតប្រជែង និងទាក់ទាញទុនវិនិយោគបន្ថែម និងបង្កើតការងារថ្មីៗជូនប្រជាពលរដ្ឋ»។

សូមបញ្ជាក់ថា ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូបសម្រាប់ ឆ្នាំ២០២៣ មានចំនួន២០០ដុល្លារអាមេរិកក្នុង១ខែ។

បន្ទាប់ពីប្រាក់ឈ្នួលកម្មករនិយោជិកត្រូវបានតម្លើងនេះហើយ នាយករដ្ឋមន្ត្រី ក៏បានអំពាវអំពាវនាវដល់ម្ចាស់ផ្ទះជួលទាំងអស់ ត្រូវរក្សាថ្លៃជួលដើម្បីរក្សានូវប្រភពចំណូលរបស់ខ្លួនឯងផង ជួយដល់កម្មករនិយោជិត និងជួយរួមចំណែកដល់ការអនុវត្តច្បាប់ស្តីពីភិតិសន្យាពិសេសដែលនៅជាធរមានផង។

សម្តេចថា ៖ «រាជរដ្ឋាភិបាលនឹងខិតខំតភ្ជាប់បណ្តាញអគ្គិសនី និងបណ្តាញទឹកស្អាតដល់គ្រប់បន្ទប់ជួល ដើម្បីជួយដល់ម្ចាស់ផ្ទះជួល និងជួយដល់បងប្អូនកម្មករនិយោជិតដែលជាអ្នកជួលបន្ទប់»។

តំណាងភាគីនិយោជក លោក ណាង សុធី ថា ការតម្លើងចំនួន៤ដុល្លារបន្ថែមនេះ ជាតួលេខមួយដែលអាចទទួលយកបាន ហើយក៏ស័ក្តិសមដែលភាគីរោងចក្រ សហគ្រាស អាចទទួលយកបាន តែជាមួយគ្នានេះខាងនិយោជកក៏មានស្នើឱ្យរាជរដ្ឋាភិបាលក្នុងការសម្រួលតម្លៃភស្តុភាកម្មដែលកន្លងមករាជរដ្ឋាភិបាលមិនទាន់បានយកចិត្តទុកដាក់។

លោកថា ភាគីសហជីពសង្ឃឹមថាអាណត្តិទី៧នេះ លោកនាយករដ្ឋមន្ត្រីនឹងពិចារណាកាត់បន្ថយភស្តុភាកម្មដែលជាបន្ទុកបន្ថែមលើការដឹកជញ្ជូនវាយនភណ្ឌ ដែលយើងរំពឹងថាអាចនឹងថយចុះ៣០%។

ចំណែក ភាគីសហជីពដែលជាតំណាងកម្មករ លោក គឹម ចាន់សំណាង បានលើកឡើងដែរថា សហជីពពេញចិត្តចំពោះតួលេខនេះដែលជាលទ្ធផលចុងក្រោយសម្រាប់ការផ្តល់ជូនដល់កម្មករនិយោជិក ដោយសារជាធម្មតាការតម្លើងប្រាក់ឈ្នួលតែងតែមានការស្រាវជ្រាវលើទន្នីករណ៍ទាំង៧ចំណុច ប៉ុន្តែក៏ត្រូវមើលទៅលើការប្រកួតប្រជែងប្រទេសជិតខាងផងដែរ។

លោកបានថ្លែងថា ៖ «នៅពេលដែលការតម្លើងប្រាក់ឈ្នួលដែលអាចទទួលយកបាន លោកគិតថា ការបញ្ជាទិញនឹងមានការកើនឡើង ហើយចំនួនសមាជិកក្នុងគ្រួសាររបស់កម្មករនិយោជិកក៏នឹងកើនចំនួនអ្នកដែលអាចមានការងារធ្វើផងដែរ ដែលធ្វើឱ្យជីវភាពរបស់ពួកគាត់មានភាពល្អប្រសើរ»។

កម្មការិនីមួយរូបនៅរោងចក្រ ខាលីនតុន ខេត្តកំពង់ចាម បានបង្ហាញការខកចិត្តបន្តិចទាក់ទងនឹងចំនួននៃការតម្លើងប្រាក់ឈ្នួលនេះ ដោយអ្នកស្រីថា សម្រាប់តួលេខនៃការឡើងប្រាក់ឈ្នួលសម្រាប់ឆ្នាំ ២០២៤ បានតែ៤ដុល្លារវាតិចពេក ប៉ុន្តែក៏ល្អដែរ។

អ្នកស្រីថា ៖ «ការតម្លើងចំនួន៤ដុល្លារបន្ថែមនេះក៏អ្នកស្រីទទួលយកបានដែរ ព្រោះរាជរដ្ឋាភិបាលនៅតែបន្តយកចិត្តទុកដាក់ដល់កម្មករនិយោជិកដែលធ្វើការនៅតាមរោងចក្រសហគ្រាស»។

កម្មការិនី ធួក ចន្ធូ នៅរោងចក្រហ្គ៊ែងយ៉ាងលេបឺល (ខេមបូឌា) អិលធីឌី បានប្រាប់ឱ្យដឹងថា ការតម្លើងប្រាក់ឈ្នួល៤ដុល្លារបន្ថែមនេះជារឿងសមរម្យមួយដែរ ព្រោះសេដ្ឋកិច្ចពេលនេះពិបាក បើកម្មករចង់បាន ឬទាមទារច្រើនពេកខ្លាចរោងចក្របិទដែលអាចធ្វើឱ្យកម្មករពិបាក។

កញ្ញា បានបញ្ជាក់ថា ៖ «ខ្ញុំអរគុណដល់រដ្ឋាភិបាល ដែលនៅតែជួយដោះស្រាយឱ្យកម្មករកម្មការិនី បើទោះបីជាស្ថានភាពសេដ្ឋកិច្ចពិបាកក៏ដោយ។ គាត់ (នាយករដ្ឋមន្ត្រី) យកចិត្តទុកដាក់ដល់កម្មករ នៅតែយកចិត្តទុកដាក់ និងខិតខំជួយដោះស្រាយតម្លើងប្រាក់ខែឱ្យកម្មករ»។

ចំណែក កម្មការិនី ទូច ស្រីនិច ធ្វើការនៅរោងចក្រហ្គ៊ែនយ៉ាងលេបឺល បានលើកឡើងដែរថា ៖ «ខ្ញុំសប្បាយចិត្តនៅពេលទទួលបានការតម្លើង៤ដុល្លារ មិនមែនបានន័យថាមិនចង់បានច្រើនជាងនេះទេ តែបើបានលើសនេះវាក៏មិនជាល្អសម្រាប់កម្មករដែរ ព្រោះខ្លាចថៅកែបិទរោងចក្រអត់ការងារធ្វើ។

កម្មការិនីរូបនេះក៏បានសំណូមពរផងដែរ កុំឱ្យម្ចាស់ផ្ទះ ឬបន្ទប់ជួល ឡើងថ្លៃឈ្នួល រួមនឹងតម្លៃទំនិញផ្សេងៗកុំមានការឡើងថ្លៃ។

កម្មការិនី ទូច ស្រីនិច បានបញ្ជាក់ថា៖ «អត្រា ៤ដុល្លារ វាតិច តែបើគិតទៅលើចំនួនកម្មករកម្មការិនីក្នុងមួយរោងចក្រៗគឺច្រើនណាស់។ បើសិនជាយើងធ្វើការថែមម៉ោងបន្ថែមនោះអាចបានច្រើនជាងមុនដែរ»។

> រាជរដ្ឋាភិបាលនឹងខិតខំតភ្ជាប់បណ្តាញអគ្គិសនី និងបណ្តាញទឹកស្អាតដល់គ្រប់បន្ទប់ជួល ដើម្បីជួយដល់ម្ចាស់ផ្ទះជួល និងជួយដល់បងប្អូនកម្មករនិយោជិតដែលជាអ្នកជួលបន្ទប់

ទាក់ទងនឹងការតម្លើងប្រាក់ឈ្នួលនេះដែរ សហជីព តំណាងកម្មករនិយោជិត អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ធ្វើការលើវិស័យ សិទ្ធិការងារ និងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា បានសម្តែងនូវការខកចិត្តជាខ្លាំង ដែលកម្មករនិយោជិតពុំអាចទទួលបានប្រាក់ឈ្នួលអប្បបរមា ២១៣ ដុល្លារក្នុងមួយខែ នៅឆ្នាំ២០២៤ ។

យោងតាមសេចក្តីថ្លែងការណ៍របស់ក្រុមអង្គការសហជីពជាង១០ស្ថាប័ន បានលើកឡើងថា ថ្មីៗនេះ របកគំហើញនៃការសិក្សាស្រាវជ្រាវដោយក្រុមអង្គការជាតិ អន្តរជាតិ និងក្រុមសហជីពឯករាជ្យ បង្ហាញពីការថយចុះប្រាក់ចំណូល ការកើនឡើងនៃការចំណាយលើការរស់នៅ និងកំណើនបំណុលនៅក្រោយវិបត្តិកូវីដ-១៩ ។

ប្រភពដដែលបន្តថា ការរកឃើញបានបង្ហាញថា កម្មករភាគច្រើនជំពាក់បំណុលក្នុងអំឡុងពេលបិទខ្ទប់ដោយសារវិបត្តិកូវីដ-១៩ ហើយពួកគេមិនមានលទ្ធភាពសងបំណុលនោះទេ។

ក្រុមសហជីព តំណាងកម្មករនិយោជិត ស្នើសុំទៅកាន់រាជរដ្ឋាភិបាលពិចារណាលើចំណុចមួយចំនួនដូចជា៖ ស្នើដំឡើងប្រាក់ឈ្នួលអប្បបរមាឲ្យបាន ២១៣ ដុល្លារក្នុងឆ្នាំ២០២៤, ពិចារណារយៈពេលខ្លីក្នុងការដំឡើងប្រាក់ឈ្នួលចន្លោះ ៣០០ ទៅ ៥០០ ដុល្លារ សម្រាប់រយៈពេលវែង, កាត់បន្ថយអតិផរណាផ្នែកចំណីអាហារ ថ្លៃសាំង និងការអនុវត្តច្បាប់លើផ្ទះជួលឲ្យមានប្រសិទ្ធភាព,ដាក់ចេញនូវវិធានការបន្ទាន់ក្នុងការពិនិត្យ និងពិចារណាក្នុងការទម្លាក់ថវិកាជាតិដើម្បីសម្រួលលក្ខខណ្ឌបំណុល (ពន្យារការបង់ប្រាក់ដើម និង និងការប្រាក់) រួមនឹងចំណុចមួយចំនួនទៀត៕

# កម្ពុជាអាចនាំចេញស្បៀងលើសពី១.២០០ លាន ដុល្លារនៅក្នុងរយៈពេល ៩ ខែដើមឆ្នាំ

*អត្ថបទ៖អរិយបុត្រ*

សហព័ន្ធស្រូវអង្ករកម្ពុជាបានអះអាងជាផ្លូវការថា នៅក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០២៣កន្លងមកនេះកម្ពុជាអាចនាំចេញស្បៀងនៅក្នុងបរិមាណលើសពី ១ ២០០ លានដុល្លារ។

យោងតាមរបាយការណ៍ដែលចេញផ្សាយដោយសហព័ន្ធស្រូវអង្ករកម្ពុជាថ្មីៗនេះបានបញ្ជាក់យ៉ាងច្បាស់ថា ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២៣ កម្ពុជាអាចនាំចេញ អង្ករសរុបចំនួនជាង ៤៥ ម៉ឺនតោន មានទឹកប្រាក់ចំនួនជាង ៣២៧ លានដុល្លារ ដោយឡែកស្រូវវិញគឺអាចនាំចេញ បានដល់ទៅជាង ៣ លានតោន ជាមួយនឹងទឹកប្រាក់សរុបជាង ៨៦២ ដុល្លារ ។



ប្រភពដដែលបានបន្តថា នៅក្នុងរយៈពេលនេះការនាំអង្កររបស់កម្ពុជាសម្រេចបានចំនួន ៤៥៦ ៥៨១ តោននាំចេញដោយក្រុមហ៊ុននាំចេញអង្ករចំនួន ៥៥ក្រុមហ៊ុន ទៅកាន់គោលដៅចំនួន ៥៧ ដោយឡែកស្រូវវិញគឺបានត្រឹមតែប្រទេសជិតខាងប៉ុណ្ណោះ គឺនៅក្នុងបរិមាណសរុប ៣.០៧ លានតោន កើនឡើងរហូតដល់ទៅ ៥៩ ភាគរយឯណោះ ។

លោក លន់ ពិសី ជាកសិករនៅស្រុកអន្លង់វែង ខេត្តឧត្តមានជ័យបានអោយកាលពីពេលថ្មីៗកន្លងទៅនេះថា រឿងតម្លៃអង្ករលោកមិនបានដឹងនោះទេ ប៉ុន្តែប្រសិនបើស្រូវនៅក្នុងឆ្នាំនេះ តម្លៃបានគ្រាន់បើ។

លោក ពិសី ដែលកំពុងតែបង្កបង្កើនផលស្រូវនៅលើផ្ទៃដីប្រមាណជា ៥ ហិចតា បានរៀបរាប់ ទាំងស្នាមញញឹមថា ពីរឆ្នាំហើយតម្លៃស្រូវដូចជាគ្រាន់បើ មែនទែន ដោយមកដល់ពេលនេះ ទោះបីជារឿងចុងដៃក៏ដោយក៏តម្លៃស្រូវសើមក៏អាចលក់បាន ពី ១ ០០០ ទី ១ ២០០ រៀលដែលនៅក្នុងមួយគក ។

ដូចគ្នានេះដែរ លោកស្រី ផល សុភ័ណ្ឌ ជាកសិករនៅខេត្តកំពង់ធំ ក៏បានឲ្យដឹងផងដែរថា តម្លៃស្រូវពេលទុំជោនៅតាមវាលស្រែ ពីមុនធ្លាក់ដល់មួយគីឡូក្រាម ៧០០ទៅ ៨០០០ រៀល ប៉ុន្តែឆ្នាំនេះ ថោកបំផុតគឺ ១ ០០០ រៀលនៅក្នុងមួយគីឡូក្រាម ហើយអ្នកខ្លះអាចលក់បានដល់ទៅ ប្រហែលជា ១ ៣០០ រៀលឯណោះនៅក្នុងមួយគីឡូក្រាម ។

តម្លៃស្រូវ/អង្ករនៅពេលនេះប្រសើរ ខណៈដែលតម្រូវការស្បៀងជាបញ្ហាដ៏សើបមួយនៅលើពិភពលោក សូម្បីតែអាស៊ានក៏កំពុងតែមានបញ្ហាដែរ ដូចជាករណីនៅម៉ាឡេស៊ី និង ហ្វីលីពីន ។

ដោយសារតែកសិករនៅក្នុងប្រទេសទាំងពីរនេះមិនអាចផ្គត់ផ្គង់អង្ករបានគ្រប់គ្រាន់ គឺប្រទេសទាំងពីរនេះ តែងនាំចូលពីប្រទេសនានា ជាពិសេសគឺវៀតណាម ហើយនៅពេលនេះ កំពុងតែមានវិបត្តិ។

យោងទៅតាមសេចក្ដីប្រកាសរបស់សហព័ន្ធស្រូវអង្ករកម្ពុជា បានឲ្យដឹងថា តម្លៃស្រូវសើមនៅកម្ពុជាកាលពីថ្ងៃទី ០៦ ខែ តុលា នៅក្នុងមួយគីឡូក្រាមថ្លៃ ពី ១ ១១០ រៀលទៅដល់ ១ ២២០ រៀល៕

# ត្រីបបែលយក្សទឹកសាបទម្ងន់ ៣០០គីឡូក្រាម ត្រូវបានបំបែកឯកទគ្គកម្មជាត្រីទឹកសាបដ៏ធំបំផុតនៅលើលោក ដោយ Guinness World Records

*អត្ថបទ៖ អមរិន្ទ ដានុត*

ត្រីបបែលយក្សរបស់កម្ពុជា ដែលមានទម្ងន់ ៣០០គីឡូក្រាម ដែលក្រុមការងារអច្ឆរិយភាពនៃទន្លេមេគង្គ (Wonder of the Mekong) បានកឹបស្លាក និងដោះលែងទៅក្នុងទន្លេមេគង្គវិញកាលពីឆ្នាំមុន ត្រូវបាន Guinness World Records ទទួលស្គាល់ជាផ្លូវការថាជាត្រីទឹកសាបដ៏ធំបំផុតនៅលើពិភពលោក។

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានប្រកាសអបអរសាទរ និងថ្លែងអំណរគុណដល់ក្រុមការងារអច្ឆរិយភាពនៃទន្លេមេគង្គ គ្រប់រូបដែលបានជួយឱ្យការណ៍នេះអាចសម្រេចទៅបាន។





ក្រសួងបន្តថា ចាប់តាំងពីធ្វើការដោះលែងវាមក ក្រុមការងារបានប្រមូលព័ត៌មានដែលមិនអាចកាត់ថ្លៃបានពីត្រីបបែលដ៏អស្ចារ្យនេះ តាមរយៈប្រព័ន្ធទទួលសញ្ញា acoustic ហើយវានឹងជួយការពារប្រភេទសត្វជិតផុតពូជនេះផងដែរ។

ក្រុមការងារអច្ឆរិយភាពនៃទន្លេមេគង្គ បានលើកឡើងថា ៖ «ត្រីបបែលយក្សទឹកសាបទម្ងន់ ៦៦១ ផោន (៣០០គីឡូក្រាម) ដែលក្រុមការងារអច្ឆរិយភាពនៃទន្លេមេគង្គ (Wonder of the Mekong) របស់យើងបានកឹបស្លាក និងដោះលែងទៅក្នុងទន្លេមេគង្គវិញកាលពីឆ្នាំមុន ត្រូវបានទទួលស្គាល់ជាផ្លូវការដោយ Guinness World Records ថាជាត្រីទឹកសាបដ៏ធំបំផុតនៅលើពិភពលោក»។

សូមរម្លឹកថា កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២កន្លងទៅ ក្រុមការងារអច្ឆរិយភាពនៃទន្លេមេគង្គ រួមជាមួយនឹងអ្នកពាក់ព័ន្ធផ្សេងទៀត បានទទួលជោគជ័យក្នុងការបំពាក់ឧបករណ៍ Acoustic និងលែងត្រីទឹកសាបដ៏ធំបំផុតក្នុងកំណត់ត្រា នោះគឺត្រីបបែលយក្សទឹកសាបទន្លេមេគង្គ។

ត្រីបបែលយក្សដ៏ធំអស្ចារ្យនេះ គឺជាប្រភេទសត្វរស់នៅខាងក្រោមបាតទន្លេ ដោយចំណាយពេលភាគច្រើននៃជីវិតរបស់ពួកវារស់នៅបាតនៃជម្រកដែលមានដីខ្សាច់ និងភក់ ហើយវាស៊ីត្រីតូចៗ និងសត្វឆ្អឹងផ្សេងៗទៀត។

ត្រីបបែលទឹកសាបដ៏ធំបំផុតដែលគេចាប់បាន និងកត់ត្រានៅថ្ងៃទី១៤ ខែមិថុនា មានប្រវែងប្រហែល ១៣ហ្វីត (ជិត៤ម៉ែត្រ) និងមានទម្ងន់ ៦៦១ផោន បើប្រៀបធៀបទៅ គឺវាមានទំងន់ ២ដងធ្ងន់ជាងទំងន់ជាមធ្យមនៃសត្វខ្លាឃ្មុំឈ្មោលពេញវ័យដែលរស់នៅតំបន់ទំនាប។

អ្នកវិទ្យាសាស្ត្របានប្រសិទ្ធនាមត្រីបបែលយក្សនេះថា «បូណ៌មី» ដែលមានន័យថា «ព្រះចន្ទពេញវង់/បូណ៌មី»។

អ្នកស្រី ឃែរី តៃលស័មេន នាយិការបេសកកម្មនៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ USAID បានលើកឡើងថា ទន្លេមេគង្គដែលហូរកាត់ប្រទេសចំនួនប្រាំមួយក្នុងតំបន់អាស៊ី គឺជាជង្រុកនៃជីវៈចម្រុះរបស់សាកលលោក និងជាជម្រករបស់ត្រីប្រមាណជិត១០០០ប្រភេទដោយរួមទាំងបបែលយក្សទឹកសាបនេះផងដែរ។

អ្នកស្រីបន្ថែមថា៖ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ USAID មានមោទកភាពណាស់ក្នុងការចូលរួមការពារអច្ឆរិយភាពទន្លេមេគង្គ និងការពារប្រភេទពូជត្រីដែលជិតផុតពូជដើម្បីជួយទ្រទ្រង់ធនធានជលផលកម្ពុជាឲ្យមានកាន់តែសម្បូរបែបដើម្បីជាប្រយោជន៍ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់»។

ជាសាកល អង្គការសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (IUCN) បានវាយតម្លៃថាសត្វបបែលយក្ស ជាសត្វកំពុងរងគ្រោះថ្នាក់ជិតផុតពូជ ដោយសារតែចំនួនរបស់វាបានថយចុះ រហូតដល់ ៧៩% ក្នុងសតវត្សចុងក្រោយនេះ។

សូមបញ្ជាក់ថា បបែលទាំងអស់នៅក្នុងប្រទេសកម្ពុជា រាប់ទាំងនៅក្នុងទឹកសាប និងទឹកប្រៃមាន ១៥ ប្រភេទ ប៉ុន្តែចំពោះប្រភេទបបែលយក្សទឹកសាបខាងលើ ជាប្រភេទមួយកំពុងរងគ្រោះទៅរកការជិតផុតពូជ ព្រោះសត្វបបែលប្រភេទនេះមិនសម្បូរទេ នៅតាមទន្លេមេគង្គ។

ត្រីបបែលយក្សមានតែនៅខាងប្រទេសឡាវ ថៃ និងខ្មែរ មានតែ ៣ ប្រទេសហ្នឹងទេ ហើយវានៅតែតាមបណ្ដោយខ្សែទឹកទន្លេមេគង្គ៕

# កញ្ញា សូ សុភក្តិណា៖ វិស័យស្ថាបត្យកម្ម ជាវិស័យអាទិភាពនិងជាគ្រឹះដ៏រឹងមាំ នៃការអភិវឌ្ឍសង្គមជាតិ



*អត្ថបទ៖ ម៉ុត ពេជ្រហ្សាលីន*

ខណៈពេលដែលវិស័យសំណង់នៅកម្ពុជារីកលូតលាស់យ៉ាងឆាប់រហ័សនាប៉ុន្មានឆ្នាំចុងក្រោយនេះ គេសង្កេតឃើញថា វិស័យស្ថាបត្យកម្មក៏មានតម្រូវការច្រើនដែរក្នុងទីផ្សារសំណង់នៅកម្ពុជា។

ដោយមើលឃើញពីសារៈសំខាន់នៃវិស័យស្ថាបត្យកម្ម អ្នកនាំសារបានធ្វើបទសម្ភាសជាមួយកញ្ញា សូ សុភក្តិណា ស្ថាបត្យករនារីខ្មែរមួយរូបបានបញ្ចប់ការសិក្សាជំនាញផ្នែកស្ថាបត្យកម្មមកពីចក្រភពអង់គ្លេស និងបច្ចុប្បន្នកញ្ញាជាស្ថាបនិកក្រុមហ៊ុន ស្ថាបត្យកម្ម LMK ដើម្បីចែករំលែកបទពិសោធន៍សំខាន់ៗជុំវិញជំនាញស្ថាបត្យកម្ម ដល់សិស្ស និស្សិត និងសាធារណជនទូទៅ ឱ្យបានយល់ពីការវិវត្តនៃវិស័យស្ថាបត្យ កម្មនៅកម្ពុជា។

*១.តើកញ្ញាយល់យ៉ាងណាចំពោះការរចនាប្លង់សំណង់អគារនៅកម្ពុជា ទើបកញ្ញាសម្រេចចិត្តសិក្សាអាជីពជាស្ថាបត្យករ?*

កញ្ញា សូ សុភក្តិណា៖ វិស័យស្ថាបត្យកម្ម និងសំណង់ នៅក្នុងប្រទេសកម្ពុជា ជាវិស័យអាទិភាពទី១ និងជាគ្រឹះដ៏រឹងមាំនៃការអភិវឌ្ឍសង្គមជាតិ។ លើសពីនេះទៀត ខ្ញុំអាចនិយាយបានថា វាគឺជាចំណង់ចំណូលចិត្ត និងភាពស្ទាត់ជំនាញរបស់ខ្ញុំតាំងពីក្មេងចំពោះគម្រោងប្លង់ ពិសេសខ្ញុំស្រឡាញ់អ្វីដែលជាសម្បត្តិវប្បធម៌របស់ជាតិខ្មែរយើង។ ខ្ញុំគិតថា ប្រទេសកម្ពុជាមានអរិយធម៌ខ្ពង់ខ្ពស់ខាងស្ថាបត្យកម្មសំណង់ ជាក់ស្តែងប្រាសាទអង្គរវត្តត្រូវបានគេចាត់ចូលជាសម្បត្តិបេតិកភណ្ឌមនុស្សជាតិ និងពិភពលោកទៀតផង ហេតុដូចនេះហើយទើបធ្វើឱ្យខ្ញុំមានមោទនភាពចំពោះវិស័យនេះ។

*២.ហេតុអ្វីបានជាវិស័យស្ថាបត្យកម្មសំណង់នៅកម្ពុជាមានការផ្លាស់ប្តូរខុសពីមុន?*

កញ្ញា សូ សុភក្តិណា៖ ពិតណាស់ការរចនាផ្នែកខាងក្នុង និងផ្នែកខាងក្រៅ របស់លំនៅដ្ឋាននីមួយៗ សុទ្ធតែបង្កប់នូវស្នាដៃសិល្បៈនៃការរស់នៅរបស់ប្រជាជនខ្មែរ។ ស្ថាបត្យកម្មសំណង់ខ្មែរកាលពី១០ឆ្នាំមុន មានលក្ខណៈស្មុគស្មាញដែលធ្វើឱ្យការរស់នៅគ្មានផាសុកភាព ហើយការរចនាប្លង់នៅពេលនោះក៏មិនទាន់បានបញ្ចូលរចនាប័ទ្មបែបទំនើបនៅឡើយទេ ពិសេសគឺបានបង្កប់នូវលក្ខណៈវប្បធម៌ជាតិតិចតួចប៉ុណ្ណោះ។

ខ្ញុំគិតថា កាលពីសម័យសង្គមរាស្ត្រនិយម ប្រជាពលរដ្ឋខ្មែរ បានបោះបង់ចោលគំនិតអភិវឌ្ឍន៍លំនៅដ្ឋានចោល ដោយនៅពេលនោះប្រជាពលរដ្ឋម្នាក់ៗគ្រប់រូបគិតគូរតែពីជីវភាពរស់នៅប៉ុណ្ណោះ។ប៉ុន្តែចាប់តាំងពីឆ្នាំ២០២០មកដល់ពេលបច្ចុប្បន្ននេះស្ថានភាពនៃការវិនិយោគវិស័យសំណង់ បានកើនឡើង ហើយការច្នៃម៉ូដគម្រោងប្លង់លំនៅដ្ឋានក៏ត្រូវបានបញ្ចូលលក្ខណៈសិល្បៈជាតិល្អប្លែកច្រើនជាងពីមុន ទាំងផ្នែកខាងក្នុង និងផ្នែកខាងក្រៅអគារ។ ម្យ៉ាងវិញទៀត អ្នកដែលមានចំណេះដឹងក្នុងវិស័យស្ថាបត្យកម្ម និងសំណង់ ក៏មានចំនួនច្រើនគួរឱ្យកត់សម្គាល់ផងដែរ នាពេលបច្ចុប្បន្ននេះ។

> ទីផ្សារអចលនទ្រព្យកម្ពុជា បច្ចុប្បន្ន មិនខ្វះទេ សម្រាប់សិស្សនិស្សិតដែលជាស្ថាបត្យករក្នុងស្រុកពោលឲ្យតែនិស្សិតមានសមត្ថភាពពិតប្រាកដ មិនខ្វះទេការងារ ព្រោះគេប្រាកដជាត្រូវការយើង ជាក់ស្តែងស្ថាបត្យករខ្មែរយើងជើងចាស់ជាច្រើនត្រូវបានទទួលស្គាល់ ហើយត្រូវបានបរទេសជួលទៅធ្វើការងារឱ្យវិញក៏មាន

*៣. តើវិស័យស្ថាបត្យកម្មដើរតួនាទីសំខាន់ប៉ុណ្ណាសម្រាប់កម្ពុជា?*

កញ្ញា សូ សុភក្តិណា៖ តាមពិតទៅ ស្ថាបត្យកម្មជាជំនាញមួយដែលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ពិភពលោក មិនមែនសម្រាប់តែកម្ពុជានោះទេ។ ប្រទេសទាំងអស់សុទ្ធសឹងតែមានស្ថាបត្យកម្ម និងរចនាបថ សម្រាប់ប្រទេសគេរៀងខ្លួន។ សម្រាប់កម្ពុជាក៏ដូចគ្នា ដូនតាយើងបានបន្សល់ទុកស្នាដៃស្ថាបត្យកម្មច្រើនណាស់ដូចជាស្នាដៃសំណង់អគារប្រាសាទបុរាណជាដើម សុទ្ធតែបានបង្កប់ដោយស្ថាបត្យកម្ម រចនាបថ និងសិល្បៈល្អៗជាច្រើន។

*៤. តើជំនាញ និងទីផ្សារស្ថាបត្យកម្មនៅកម្ពុជាមានតម្រូវការ និងសក្តានុពលយ៉ាងដូចម្តេច?*

កញ្ញា សូ សុភក្តិណា៖ សម្រាប់ជំនាញនេះវាមានសក្តានុពលខ្ពស់ ព្រោះសំណង់អគារ នាពេលបច្ចុប្បន្ននេះកំពុងរីកដុះដាលយ៉ាងច្រើន។ បើទោះបីជាបច្ចុប្បន្ននេះមាននិស្សិតសិក្សាជំនាញស្ថាបត្យកម្មច្រើនក៏ដោយក៏ថ្ងៃក្រោយនៅតែមានតម្រូវការខ្ពស់ដដែលព្រោះនៅទីក្រុងយើងនៅត្រូវការអគារនិងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតទាំងស្ពាន អគារធំៗ និងលំនៅឋានជាដើម។

ជាក់ស្តែងនាបច្ចុប្បន្ននេះ វិស័យនេះកំពុងត្រូវប៉ាន់ខ្លាំង ព្រោះមានគម្រោងធំៗជាច្រើនកំពុងសាងសង់ ដូចជា៖ ខុនដូ សណ្ឋាគារ បុរីលំនៅឋានបែបទំនើប សំណង់ផ្ទះល្វែង និងការឌីហ្សាញលើភោជនីដ្ឋាន និងហាងកាហ្វេជាដើម។ ម្ចាស់គម្រោងភាគច្រើន ចង់បានគម្រោងប្លង់បែបទំនើប ប៉ុន្តែក៏មានគម្រោងបែបបុរាណខ្លះដែរ ដូចជា ប្លង់សណ្ឋាគារនៅខេត្តសៀមរាបដើម។

*៥. តើជាទូទៅម្ចាស់គម្រោងត្រូវចំណាយប្រាក់ចាប់ពីប៉ុន្មាន ទៅលើគម្រោងប្លង់នីមួយៗ?*

កញ្ញា សូ សុភក្តិណា៖ យើងមិនអាចកំណត់ពីតម្លៃច្បាស់លាស់ ពីការចំណាយរបស់ម្ចាស់គម្រោងទៅលើការជួលស្ថាបត្យករក្នុងការឌីហ្សាញប្លង់ ឬក៏គូសប្លង់លើគម្រោងណាមួយបានឡើយ ព្រោះវាអាស្រ័យលើទំហំគម្រោងថាតើជាប្រភេទធំ ឬតូច និងអាស្រ័យទៅលើសមត្ថភាពរបស់ស្ថាបត្យករផ្ទាល់តែម្តង តើអាចផ្តល់ទំនុកចិត្ត និងភាពជឿជាក់កម្រិតណា ដល់ម្ចាស់គម្រោងនីមួយៗ។

យ៉ាងណាតម្លៃដែលស្ថាបត្យករទទួលបាននៅក្នុងទីផ្សារអចលនទ្រព្យកម្ពុជាក៏មានការប្រកួតប្រជែងជាមួយស្ថាបត្យករបរទេសខ្លះផងដែរ ព្រោះមានម្ចាស់គម្រោងមួយចំនួនមិនទាន់ជឿជាក់លើសមត្ថភាព របស់ស្ថាបត្យករក្នុងស្រុកនៅឡើយ។

*៦. តើទីផ្សារស្ថាបត្យកម្មមានការប្រកួតប្រជែងកម្រិតណាដែរ?*

កញ្ញា សូ សុភក្តិណា៖ បច្ចុប្បន្នសមត្ថភាពស្ថាបត្យករខ្មែរ អាចប្រកួតប្រជែងជាមួយស្ថាបត្យករបរទេសបាន ប៉ុន្តែគ្រាន់តែមានម្ចាស់គម្រោងខ្លះនៅមានផ្នត់គំនិតចង់បានស្ថាបត្យករបរទេសច្រើនជាង។

ទីផ្សារអចលនទ្រព្យកម្ពុជា បច្ចុប្បន្នមិនខ្វះទេ សម្រាប់សិស្សនិស្សិតដែលជាស្ថាបត្យករក្នុងស្រុកពោលឲ្យតែនិស្សិតមានសមត្ថភាពពិតប្រាកដ មិនខ្វះទេការងារ ព្រោះគេប្រាកដជាត្រូវការយើង ជាក់ស្តែងស្ថាបត្យករខ្មែរយើងជើងចាស់ជាច្រើនត្រូវបានទទួលស្គាល់ ហើយត្រូវបានបរទេសជួលទៅធ្វើការងារឱ្យវិញក៏មាន។ ហេតុនេះទីផ្សារស្ថាបត្យកម្មនេះទូលំទូលាយណាស់សម្រាប់និស្សិតកម្ពុជា ព្រោះមិនមែនមានតែទីផ្សារក្នុងស្រុកទេ តែមានទីផ្សារនៅបរទេសថែមទៀតប្រសិនបើមានសមត្ថភាពខ្លាំង។

*៧. តើនៅឆ្នាំ២០២៤ខាងមុខវិស័យស្ថាបត្យកម្មសំណង់អាចនឹងមានការវិវត្តរីកចម្រើនដល់កម្រិតណា?*

កញ្ញា សូ សុភក្តិណា៖ តាមការសិក្សាស្រាវជ្រាវរបស់ខ្ញុំកន្លងមកឃើញថា វិស័យស្ថាបត្យកម្មសំណង់មានការកើនឡើងគួរឲ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយស្ថាបត្យករខ្មែរ ក៏បានពង្រឹងគុណភាព និងបរិមាណរបស់គេដើម្បីឈានឆ្ពោះទៅមុខផងដែរ។ ខ្ញុំជឿថា ឆ្នាំ២០២៤ខាងមុខ វិស័យអចលនទ្រព្យ និងសំណង់ នឹងកាន់តែមានសកម្មភាពផុសផុលជាមិនខាន។ គោលនយោបាយរដ្ឋាភិបាលក៏កំពុងតែវិវត្តល្អបន្តិចម្តងៗ ដែលធ្វើឱ្យអ្នកវិនិយោគបរទេស អាចមកវិនិយោគនៅកម្ពុជាយ៉ាងច្រើនទាំងពេលបច្ចុប្បន្ន និងថ្ងៃអនាគត៕



# តើគេស្តារព្រៃត្រូពិចឡើងវិញបានយ៉ាងដូចម្តេច?

*អត្ថបទ៖ ផាត សំភី*

រយៈពេលជាង ២០ឆ្នាំ អ្នកសិក្សាស្រាវជ្រាវបានតាមដានការវិវត្តន៍នៃព្រៃត្រូពិចដែលកំពុងតែ ធ្លាក់អន់ថយ និងព្យាយាមប្រើវិធីសាស្ត្រផ្សេងៗគ្នា ក្នុងការស្តារឡើងវិញ។ របៀបលឿនបំផុតនៃការធ្វើឲ្យព្រៃត្រូពិច មានសភាពល្អ គឺត្រូវគិតគូទៅដល់ភាពចម្រុះ។



នៅក្នុងតំបន់ត្រូពិចភាគច្រើន ព្រៃដែលបានទាញយកធ្វើអាជីវកម្មកាន់តែរីករាលដាលទៅក្នុងព្រៃដែលពីមុនមិនធ្លាប់ត្រូវបានប៉ះពាល់។ នៅទីនោះ ការធ្វើអាជីវកម្មព្រៃឈើគឺជាការកាប់ដោយជ្រើសរើស មានន័យថា គេយកតែឈើណា ដែលមានសារៈប្រយោជន៍សម្រាប់ពួកគេ។ ព្រៃឈើមិនត្រូវបំផ្លាញទាំងស្រុងទេ បន្ទាប់ពីការធ្វើអាជីវកម្មហើយ។ ប៉ុន្តែឈើដែលនៅសេសសល់បានធ្លាក់ថយគុណភាពយ៉ាងជាក់ច្បាស់។

ព្រៃត្រូពិច ជាជម្រក ៨០% នៃពូជសត្វរុក្ខជាតិដែលគេចងក្រងឯកសាររួចហើយ និងតំណាងឲ្យប្រមាណ ៤០% នៃអណ្តូងស្តុកកាបូននៅលើពិភពលោក។ ការស្តារឡើងវិញនូវប្រព័ន្ធបរិស្ថានទាំងនេះ គឺមានសារៈសំខាន់ចាំបាច់ដើម្បីប្រយុទ្ធប្រឆាំងនឹងវិបត្តិទ្វេនៃការប្រែប្រួលអាកាសធាតុ និងការធ្លាក់ចុះសឹករិចរិលនៃស្ថានជីវចម្រុះ។

នៅឆ្នាំ២០០២ នៅកោះប័រណេអូ នៅប្រទេសម៉ាឡេស៊ី អ្នកសិក្សាស្រាវជ្រាវ បានដាំដុះឈើជិត ១០០០០០ ដើម នៅលើទំហំដី ៥០០ ហិចតានៃព្រៃត្រូពិច ដែលបានរងការកាប់បំផ្លាញ។ ការវិភាគអំពីស្ថានភាពព្រៃឈើនេះ មានរយៈពេលជាង ២០ឆ្នាំ មកហើយ និងបន្តធ្វើជារៀងរហូត។

ដើម្បីធ្វើតេស្តវិធីសាស្ត្រផ្សេងៗ នៃការស្តារឡើងវិញ ព្រៃឈើទាំងមូលត្រូវបានបែងចែកជា ១២៥ តំបន់។ តំបន់ខ្លះត្រូវបានទុកចោលដើម្បីជាប្រយោជន៍ឲ្យឈើដុះដាលជាធម្មជាតិនៅខណៈដែលតំបន់ខ្លះត្រូវបានដាំដុះឡើងវិញ ដោយការលាយគ្នារវាង ១ ៤ ឬ ១៦ ពូជដើមឈើខុសៗគ្នា។

លោកអេនឌ្រូ ហេចទ័រ សាស្ត្រាចារ្យ នៅសកលវិទ្យាល័យអ័កស្វ័ត ចក្រភពអង់គ្លេស ថ្លែងថា៖ «នេះគឺជារបៀបនៃការដាំដុះដើមឈើនាពេលបច្ចុប្បន្ន! ប៉ុន្តែវាមិនងាយស្រួលពេកនោះទេ ៖ គេត្រូវដឹងអំពីការដាំដើមឈើល្អនៅកន្លែងត្រឹមត្រូវ។ ប្រសិនបើមិនអីចឹង នេះអាចបង្កឲ្យមានបញ្ហាផ្សេងៗទៀត»។

អ្នកសិក្សាស្រាវជ្រាវដាំតែពូជឈើក្នុងស្រុក។ ឈើដែលកាប់ហើយ គេដាក់គោលដៅដាំដើម្បីជំនួសវិញ ហើយប្រមូលផ្តុំលើគ្រួសារឈើដែលគ្របដណ្តប់ភាគច្រើននៅអាស៊ីអាគ្នេយ៍ ដូចជាគ្រួសារឈើ ឌីបតេរ៉ូកាកប៉ាសេ។

ពូជពពួកនេះខុសប្លែកពីភាគច្រើននៃពូជឈើដទៃៗ ទៀត។ អ្នកសិក្សាស្រាវជ្រាវគិតថា ពួកវាគឺជាស្ថានជីវចម្រុះដើមឈើភាគច្រើនបំផុត។ ពួកអាចធ្វើឲ្យប្រព័ន្ធជីវចម្រុះអាចដុះដាលឡើងវិញកាន់តែឆាប់រហ័ស ដោយសារតែវាធ្វើឲ្យស្ថានជីវចម្រុះកាន់តែមានស្ថិរភាព និងធន់ ប្រឈមមុខនឹងលក្ខខណ្ឌប្រែប្រួល។ លោកសាស្ត្រាចារ្យរៀបរាប់ថា ៖ «ការដាំដើមឈើចម្រុះដូចជាការវិនិយោគក្នុងវិស័យជាច្រើនដើម្បីកាត់បន្ថយហានិភ័យ»។ នេះគឺដូចគ្នានៅក្នុងព្រៃត្រូពិច៖ «ស្ថានជីវចម្រុះប្រតិកម្មដូចជាការធានាឲ្យគ្នា»។

ជាឧទាហរណ៍ ពូជខ្លះអាចតស៊ូបានច្រើនចំពោះគ្រោះរាំងស្ងួត ជាងពូជផ្សេងៗទៀត ដោយសារតែវាបង្កើតសារធាតុគីមីដើម្បីការពារពួកវា។ ដូច្នេះប្រព័ន្ធជីវចម្រុះគឺកាន់តែធន់ទ្រាំនៅអំឡុងពេលដែលមានភ្លៀងធ្លាក់តិច នៅពេលដែលពូជទាំងនេះមានវត្តមាន។ នេះគឺជាអ្វីដែលកាន់តែមានសារៈសំខាន់នៅខណៈដែលបាតុភូតឧតុនិយមកាន់តែធ្ងន់ធ្ងរ។ អ្នកសិក្សាស្រាវជ្រាវក៏បានបញ្ជាក់អំពីសារៈសំខាន់នៃការការពារព្រៃដែលមិនទាន់ប៉ះពាល់ឲ្យលើសពីការកាប់ហើយស្តារឡើងវិញ ដោយសារតែ ទោះបីជាគេដាំពូជឈើ ដល់ ១៦ ពូជ នៅក្នុងព្រៃដែលសឹករិចរិល ស្ថានជីវចម្រុះ គឺនៅតែទន់ខ្សោយច្រើនជាងព្រៃដែលគេមិនទាន់ប៉ះពាល់៕

# វីរុសហ្ស៊ីកា (Zika Virus) និងការការពារ

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រសួងសុខាភិបាល បានប្រកាសឱ្យដឹងថា វីរុសហ្ស៊ីកា ឆ្លងមកមនុស្ស តាមរយៈ មូសខ្លាដែលមានផ្ទុកវីរុសហ្ស៊ីកាខាំ។ ប្រភេទមូសខ្លានេះគឺដូចគ្នានឹងមូសខ្លាដែលផ្ទុកវីរុសជំងឺគ្រុនឈាម និងគ្រុនឈីក។




វីរុសជំងឺហ្ស៊ីកា អាចឆ្លងតាមការរួមភេទជាមួយអ្នកដែលផ្ទុកវីរុសហ្ស៊ីកាពីព្រោះ វីរុសនេះមាននៅក្នុងទឹកកាម ឈាម ទឹកនោម ទឹកភ្នែក ទឹកមាត់ ព្រមទាំងសារធាតុរាវរាង្គកាយ នៅក្នុងខួរក្បាល និងខួរឆ្អឹងខ្នង។ វីរុសហ្ស៊ីកាឆ្លងពីម្តាយទៅកូនក្នុងអំឡុងមានផ្ទៃពោះ និងនៅពេលសម្រាល។

វីរុសហ្ស៊ីកា ជាធម្មតាបណ្តាលឱ្យមានជំងឺហ្ស៊ីកាស្រាលមិនធ្ងន់ធ្ងរទេ ដែលចេញរោគសញ្ញាពី ២ ទៅ៣ថ្ងៃ បន្ទាប់ពីមនុស្សម្នាក់ត្រូវបានខាំដោយសត្វមូសខ្លាដែលផ្ទុកវីរុសហ្ស៊ីកា រោគសញ្ញាទូទៅមានដូចជាគ្រុនក្តៅស្ទើញៗ និងកន្ទួលក្រហមលើស្បែក អ្នកខ្លះទៀតអាចនឹងមាន ភ្នែកឡើងក្រហម ឈឺសាច់ដុំ ឈឺសន្លាក់ និងអស់កម្លាំងជាដើម។

រោគសញ្ញាទាំងនេះជាធម្មតាអាចជាសះស្បើយក្នុងរយៈពេលពី ២ ទៅ ៧ថ្ងៃ ហើយអត្រាស្លាប់មានកម្រិតតិចតួចណាស់។ គេបានប៉ាន់ប្រមាណថា ៨០% នៃមនុស្សដែលបានឆ្លងវីរុសនេះមិនបានបង្ហាញរោគសញ្ញាអ្វីទេ។ មានករណីតិចតួច បំផុតដែលអាចវិវត្តទៅជាទន់ដៃទន់ជើង ហើយបើកើតមានលើស្ត្រីមានផ្ទៃពោះ គឺអាចទារកស្លាប់ក្នុងផ្ទៃ ឬក្បាលទារកអាចតូចជាងធម្មតា។

**ការការពារពីវីរុសហ្ស៊ីកា**

ជំងឺហ្ស៊ីកាមិនមានការព្យាបាលជាក់លាក់ទេ ប៉ុន្តែតម្រូវឱ្យផ្តល់ការព្យាបាលគាំទ្រ និងថែទាំទៅតាមរោគសញ្ញអ្នកជំងឺ។ មនុស្សដែលមានជំងឺហ្ស៊ីកា គួរសម្រាក និងពិសាទឹកឱ្យបានច្រើន ព្រមទាំងព្យាបាលការឈឺចាប់និងគ្រុនក្ត ដោយប្រើថ្នាំបញ្ចុះកំដៅធម្មតា តែមិនតម្រូវឱ្យប្រើថ្នាំផ្សះទេ។ ប្រសិនបើរោគសញ្ញាកាន់តែធ្ងន់ធ្ងរ សូមស្វែងរកការ ពិគ្រោះជំងឺជាមួយគ្រូពេទ្យនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋដែលនៅជិតលោកអ្នក។ ការធ្វើរោគវិនិច្ឆ័យគឺតាម រយៈមន្ទីរពិសោធន៍នៅក្នុងប្រទេសកម្ពុជា៖ មន្ទីរពិសោធន៍នៅវិទ្យាស្ថានសុខភាពសាធារណៈ និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលអាចធ្វើតេស្តរកវីរុសហ្ស៊ីកាបាន។ បច្ចុប្បន្នមិនមានវ៉ាក់សាំងដែលអាចប្រើសម្រាប់បង្ការជំងឺនេះនៅឡើយទេ។

ការបង្ការដែលល្អបំផុត ពីជំងឺហ្ស៊ីកា គឺត្រូវអនុវត្តន៍ដូចទៅនឹងការបង្ការជំងឺគ្រុនឈាម និងគ្រុនឈីកដែរ រួមមានការពារខ្លួនកុំមូសខ្លាខាំ ស្ត្រីដែលមានផ្ទៃពោះ ឬមានផែនការនឹងមានផ្ទៃពោះ និងដៃគូរួមភេទរបស់គាត់រឹតតែត្រូវមានការប្រុងប្រយ័ត្នបន្ថែមទៀតដើម្បីការពារខ្លួនពីមូសខ្លាដែលមានផ្ទុកវីរុសហ្ស៊ីកាខាំ និងការចម្លងតាមការរួមភេទ។

បំបាត់ជម្រកមូសខ្លា ដោយធ្វើអនាម័យសម្អាតជុំវិញផ្ទះ ការពារកុំមានទឹកដក់នៅជុំវិញផ្ទះ លុបបំបាត់ថ្លុក សំបកកំប៉ុង សំបកកង់ឡាន ត្រឡោកដូង ធុងទឹក ផើងផ្កា និងប្រើអាបែតដាក់ក្នុងពាង ឬអាងស្តុកទឹក។ ស្លៀកពាក់ខោជើងវែង អាវដៃវែង និងស្រោមជើង ធ្វើយ៉ាងណាគ្របដណ្តប់ភាគច្រើននៃរាងកាយឱ្យជិត (សម្លៀកបំពាក់គួរតែមានពណ៌ភ្លឺ កុំខ្មៅឬងងឹត)។

ប្រើថ្នាំបាញ់ (spray) ឬលាប (repellent) កុំឱ្យមូសមកជិត ហើយថ្នាំនេះស្ត្រីមានផ្ទៃពោះអាចបើ បានដោយមានសុវត្ថិភាព មិនមានផលប៉ះពាល់ទេ។ សម្រាន្តក្នុងមុង រាល់ពេលសម្រាន្តនៅពេលយប់ និងថ្ងៃ ព្រមទាំងបើកបង្អួចឱ្យបានធំៗ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់ចេញចូលបានល្អ។

ប្រសិនជាមិនចាំបាច់ ស្ត្រីមានផ្ទៃពោះ គូស្វាមីភរិយា ឬស្ត្រីមានគម្រោងមានផ្ទៃពោះ មិនគួរឬមិនត្រូវធ្វើ ដំណើរទៅកាន់តំបន់ ដែលមានផ្ទុះ ឬកំពុងមានជំងឺហ្ស៊ីក ហើយត្រូវអនុវត្តការការពារខ្លួនឱ្យបានខ្ជាប់ខ្ជួនបំផុត៕



## អ្នកវិទ្យាសាស្ត្រពីររូបទទួលបានពានរង្វាន់ណូបែល



*អត្ថបទ៖ អរិយបុត្រ*

អ្នកវិទ្យាសាស្ត្រពីររូប គឺ លោកបណ្ឌិត ឌ្រូវ វ៉ៃស្មេន (Drew Weissman) និងលោកស្រីបណ្ឌិត កាតាលីន ការីកូ (Katalin Karikó) បានទទួលពានរង្វាន់ណូបែលវិទ្យាសាស្ត្រ ឆ្នាំ២០២៣ ។

អ្នកវិទ្យាសាស្ត្រទាំងពីរ ត្រូវបានសម្រេចផ្តល់ពានរង្វាន់នេះ គឺក្រោយពេលដែលពួកគេបានរកឃើញនូវគំរូម៉ូលេគុល mRNA ដែលបានត្រួសត្រាយផ្លូវឆ្ពោះទៅរកការផលិតនូវវ៉ាក់សាំងកូវីដ-១៩ ។

លោកបណ្ឌិតឌ្រូវវ៉ៃស្មេន គឺជាអ្នកវិទ្យាសាស្ត្រអាមេរិក និងលោកស្រីបណ្ឌិតកាតាលីន ការីកូ គឺជាអ្នកវិទ្យាសាស្ត្រដើមកំណើតហុងគ្រី។

ពានរង្វាន់នេះត្រូវបានប្រកាសដោយលោក ថូម៉ា ភ័មែន (Thomas Perlmann) អគ្គលេខាធិការពានរង្វាន់ណូបែល នៃវិទ្យាស្ថានខារ៉ូលីនស្កា (Karolinska Institute) នៅទីក្រុងស្តុកហូល ប្រទេសស៊ុយអែត៕

# ដ្រូនមានមនុស្សជិះ បង្កើតដោយក្រុមយុវជនកម្ពុជា អាចនឹងវិវត្តន៍ទៅជាតាក់ស៊ីដ្រូននាពេលអនាគត









*អត្ថបទ៖ ផល សុផានិត*

យុវជនមួយក្រុមដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) បានបង្កើតដ្រូនដែលមនុស្សអាចជិះបាន និងដឹកជញ្ជូនឥវ៉ាន់ផ្សេងៗបានផងដែរ ហើយសម្រាប់ទៅថ្ងៃខាងមុខយុវជនទាំងនេះ ក៏មានបំណងវិវត្តដ្រូននេះទៅជា «តាក់ស៊ីដ្រូន» សម្រាប់ជួយក្នុងការបាញ់ថ្នាំសម្លាប់សត្វល្អិត ឬប្រើសម្រាប់ពន្លត់អគ្គិភ័យជាដើម។

ជាកូនកសិករមកពីខេត្តបន្ទាយមានជ័យ និស្សិត ឡុញ វណ្ណសិដ្ឋ និងមិត្តរួមក្រុមបានបង្កើតដ្រូនដែលមានមនុស្សជិះបាន ដើម្បីដឹកជញ្ជូនឥវ៉ាន់ផ្សេងៗ ដោយថ្ងៃខាងមុខនឹងវិវត្តន៍ទៅជាតាក់ស៊ីដ្រូន ដ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត ឬប្រើសម្រាប់ពន្លត់អគ្គីភ័យជាដើម។

ដោយសារតែមានក្ដីសុបិនតាំងពីក្មេងចង់សិក្សាផ្នែកវិស្វកម្ម និងបច្ចេកវិទ្យាទំនើប និស្សិត ឡុញ វណ្ណសិដ្ឋ ដែលកំពុងសិក្សាឆ្នាំទី៤វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) បានសម្រេចក្ដីបំណងក្នុងការបង្កើតដ្រូនដែលអាចផ្ទុកមនុស្ស និងអាចដឹកជញ្ជូនឥវ៉ាន់ផ្សេងៗបាន ដោយមានការជួយជ្រោមជ្រែងពីលោកសាស្ត្រាចារ្យ និងមិត្តរួមក្រុម។

បើតាមនិស្សិត ឡុញ វណ្ណសិដ្ឋ បានឱ្យដឹងថា៖ «គម្រោងរបស់ខ្ញុំ ត្រូវបានបំផុសគំនិតដោយការមើលវីដេអូ YouTube ហើយឆ្លៃប្រឌិតទៅតាមលទ្ធភាពដែលខ្ញុំមាន ហើយទីបំផុតក្ដីស្រម៉ៃខ្ញុំ ក៏បានក្លាយជាការពិតដែលធ្វើឱ្យខ្ញុំ និងក្រុមក្លាយជាមនុស្សដំបូងដែលបានផលិតយន្តហោះដ្រូនដឹកមនុស្ស មុនគេនៅកម្ពុជា»។

និស្សិតវណ្ណសិដ្ឋនិយាយបន្តថា៖ «ខ្ញុំតែងតែមើល និងរៀនអំពីបច្ចេកវិទ្យាទំនើបនៅពេលខ្ញុំរៀននៅវិទ្យាល័យ ហើយជាញឹកញាប់ខ្ញុំបើកទូរសព្ទដៃចាស់ៗមើលថាមានអ្វីនៅខាងក្នុង ហើយបន្ទាប់មកខ្ញុំព្យាយាមជួសជុលវា»។

និស្សិតដដែលប្រាប់ទៀតថា ត្បិតតែឪពុកម្ដាយរបស់គេជាកសិករ ប៉ុន្តែរូបគេមានមោទនភាពចំពោះការបង្កើតឡានដ្រូន ប៉ុន្តែនៅមានរឿងជាច្រើនទៀតដែលរូបគេត្រូវរៀនសូត្របន្ថែម ហើយសម្រាប់គម្រោងយន្ត Drone នេះ រូបគេបានជួយក្នុងការបង្កើតឧបករណ៍បញ្ជាដែលជាផ្នែកមួយយ៉ាងសំខាន់។

ចំណែកនិស្សិតឆ្នាំទី៣ លោក ជ្រោយ សុធារ៉ា ក៏បានលើកឡើងដែរថា ជាញឹកញយ រូបគេឃើញប្រទេសផ្សេងទៀតផលិតរថយន្តគ្មានមនុស្សបើក ហើយរូបគេចង់ដឹងចង់ ឃើញពីរបៀបដែលពួកគេធ្វើវា។ នេះហើយជាដើមចមដែលធ្វើឱ្យយុវជន ជ្រោយ សុធារ៉ា បានចូលរួមក្នុងគម្រោងនេះដើម្បីរៀនសូត្រ និងអនុវត្តបានច្រើនជាងការរៀនទ្រឹស្ដីនៅក្នុងថ្នាក់។

លោកអះអាងថា ការបង្កើតដ្រូនមានមនុស្សបើកនេះមានការលំបាក ព្រោះរូបគេឃើញវាតែក្នុងវីដេអូតាមអ៊ីនធឺណិត ហើយគេមិនដឹងថាត្រូវចាប់ផ្ដើមពីណាមុនគេនោះទេ។ ដូច្នេះហើយបានជាក្រុមរបស់គេបានសិក្សា និងស្រាវជ្រាវខ្លះៗពីរបៀបបង្កើតវា។

លោក ជ្រោយ សុធារ៉ា បានប្រាប់ទៀតថា បន្ទាប់មក ក្រុមទាំងមូលបានរចនារូបគំនូររបស់វា ហើយពិភាក្សាជាមួយសមាជិកក្រុម ដើម្បីមើលថាតើវាល្អ និងរឹងមាំគ្រប់គ្រាន់ដែរឬទេ។ បន្ទាប់មកក្រុមរបស់គេបានបង្កើតតួយន្តហោះគ្មានមនុស្សបើក មេកានិក គ្រឿងអេឡិចត្រូនិក បន្ទាប់មករៀបចំកម្មវិធីដើម្បីបញ្ជា។

លោក ហួរ សុខអូន អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍នៃ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) បានសម្ដែងការរីករាយ ខណៈដែលសិស្សរបស់លោកបានសម្រេចក្ដីសុបិនក្នុងការបង្កើតយន្តហោះដ្រូននេះឡើង។

លោកមានប្រសាសន៍ថា៖ «មូលហេតុដែលយើងបង្កើតរថយន្ត Drone នេះ គឺដូចដែលអ្នកបានដឹងហើយថា ពិភពបច្ចេកវិទ្យាកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងប្រទេសផ្សេងៗ ដូច្នេះហើយបានជាយើងចង់អនុវត្តបច្ចេកវិទ្យាទំនើបនេះនៅក្នុងប្រទេសរបស់យើងផងដែរ»។

លោក ហួរ សុខអូន បន្ថែមទៀតថា គម្រោងយន្តហោះ Drone នេះអាចផ្ដល់ឱ្យនូវឱកាសមួយក្នុងការជួយដោះស្រាយបញ្ហាជីវិតប្រចាំថ្ងៃ ដូចជាការកកស្ទះចរាចរណ៍ជាដើម។ លោកមើលឃើញថា ផ្លូវរបស់ប្រទេសយើងតូច ហើយមានឡានច្រើន ដូច្នេះនៅពេលអនាគត លោកចង់អភិវឌ្ឍឡាន Drone នេះឱ្យទៅជាតាក់ស៊ី Drone។

លោកបញ្ជាក់ទៀតថា ដ្រូនរថយន្តនេះ ក៏អាចប្រើប្រាស់ក្នុងវិស័យកសិកម្ម ដូចជាសម្រាប់ការបង្កបង្កើនផលដំណាំ ដ្រូននេះផងដែរ។ វាអាចត្រូវបានប្រើដើម្បីពន្លត់ភ្លើង ខណៈសព្វថ្ងៃមានអគារខ្ពស់ៗជាច្រើនដែលរថយន្តពន្លត់អគ្គិភ័យមិនអាចទៅដល់បាន ដូច្នេះដ្រូននេះអាចមានប្រយោជន៍សម្រាប់កិច្ចការទាំងនេះ។

យ៉ាងណាមិញ លោកសាស្ត្រាចារ្យរូបនេះបានរៀបរាប់ថា សម្រាប់គម្រោងនេះចំណាយប្រាក់ច្រើន លោកបានស្នើសុំថវិកាពីរដ្ឋាភិបាល ដោយសារសាកលវិទ្យាល័យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ មិនតែប៉ុណ្ណោះ មានក្រុមហ៊ុនឯកជនមួយចំនួនដែលបានឧបត្ថម្ភការស្រាវជ្រាវនេះ និងមានមនុស្សជាច្រើនចាប់អារម្មណ៍លើគម្រោងរបស់និស្សិតលោក។

សូមជម្រាបផងដែរថា ដោយមើលឃើញពីការរីកចម្រើនយ៉ាងខ្លាំងក្នុងវិស័យបច្ចេកវិទ្យានៅក្នុងប្រទេសដទៃៗទៀត និស្សិតកម្ពុជាក៏បាននិងកំពុងតែខិតខំស្រាវជ្រាវផលិតឧបករណ៍ប្រើប្រាស់ទំនើបៗ ដើម្បីជាប្រយោជន៍ និងជួយស ម្រួលដល់ការរស់នៅរបស់ប្រជាជនកម្ពុជាប្រចាំថ្ងៃផងដែរ។

ទន្ទឹមនឹងនេះ គម្រោងយន្តហោះដ្រូន នេះនឹងក្លាយជាឱកាសមួយ ដើម្បីជួយដោះស្រាយបញ្ហាដូចជា ការកកស្ទះចរាចរណ៍ ដោយថ្ងៃអនាគតយន្តហោះដ្រូននេះនឹងត្រូវបាន អភិវឌ្ឍទៅជាតាក់ស៊ី Drone មិនតែប៉ុណ្ណោះ យន្តហោះដ្រូននេះក៏អាចប្រើសម្រាប់បាញ់ជីលើដំណាំកសិកម្មនៅលើអាកាស ឬបាញ់ថ្នាំសម្លាប់សត្វល្អិត ពិសេសប្រើប្រាស់សម្រាប់ពន្លត់អគ្គីភ័យ នៅតាមអគារខ្ពស់ៗ ដែលរថយន្តពន្លត់អគ្គីភ័យមិនអាចទៅដល់ផងដែរ៕

## ចំណេះដឹងទូទៅ៖

# នរណាជាស្ត្រីដំបូងគេដែលបាន ធ្វើដំណើរទៅកាន់លំហអវកាស?

*អត្ថបទ៖ ខខខខ*

នាថ្ងៃទី១៦ខែមិថុនាឆ្នាំ១៩៦៣អវកាសយានិកជនជាតិសូវៀតមួយរូបគឺលោកស្រី វ៉ាលែនទីណា តេរេសស្កូវ៉ា (Valentina Tereshkova) បានក្លាយជាស្ត្រីដំបូងគេបង្អស់ ដែលបានធ្វើដំណើរទៅក្នុងលំហអវកាសដោយជិះយានអវកាសវ៉ូស្តុក៦ (Vostok 6)។ ក្រោយគោចរជុំវិញផែនដីបាន៤៨ជុំវិញ និងចំណាយពេល៧១ម៉ោងរួចមក លោកស្រីបានវិលត្រឡប់ចុះមកផ្ទៃផែនដីវិញ។ គិតត្រឹមពេលនោះ ការធ្វើដំណើរក្នុងលំហអវកាសរបស់លោកស្រី គឺច្រើនជាងរយៈពេលនៃការធ្វើដំណើរក្នុងទីអវកាសរបស់ អវកាសយានិកអាមេរិកទាំងអស់បូកបញ្ចូលគ្នាទៀតផង។

លោកស្រី វ៉ាលែនទីណា វ្ល៉ាឌីមៀរ៉ូវណា តេរេសស្កូវ៉ា (Valentina Vladimirovna Tereshkova) កើតក្នុងគ្រួសារកសិករមួយនៅប្រទេសរុស្ស៊ី ក្នុងឆ្នាំ១៩៣៧ ដែលជាអំឡុងសម័យសហភាពសូវៀត។ លោកស្រីបានចាប់ផ្តើមការងារដំបូងនៅរោងចក្រវាយនភណ្ឌមួយកន្លែងនៅអាយុ១៨ឆ្នាំ។ លុះដល់វ័យ២២ឆ្នាំ លោកស្រីបានទទួលឱកាសធ្វើការលោតឆ័ត្រយោងជាលើកដំបូងក្រោមការឧបត្ថម្ភនៃក្លឹបអាកាសចរណ៍មួយ។

ភាពស្រឡាញ់ចូលចិត្តសកម្មភាព Skydiving (ការទម្លាក់ខ្លួនពីលើអាកាស) របស់លោកស្រី បាននាំឲ្យកម្មវិធីអវកាសរបស់សូវៀតចាប់អារម្មណ៍ខ្លាំងចំពោះលោកស្រី ខណៈសូវៀតពេលនោះកំពុងតែព្យាយាមស្វែងរកស្ត្រីអវកាសយានិក ដើម្បីបញ្ជូនឡើងទៅកាន់ទីអវកាស នៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៦០ ក្រោមគោលដៅសម្រេចជោគជ័យមួយទៀតឲ្យបានមុនសហរដ្ឋអាមេរិក។













ជាមួយបទពិសោធន៍ជាអ្នកលោតឆ័ត្រយោងដ៏ជោគជ័យមួយរូប លោកស្រី Tereshkova មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រឈមនឹងតម្រូវការយ៉ាងលំបាកមួយនៃការធ្វើដំណើរក្នុងយាន Vostok គឺការត្រូវចាកចេញពីយានអវកាសនេះ ពេលចុះមកដល់វិញនៅត្រឹមកម្ពស់ជាង៦គីឡូម៉ែត្រ ហើយទម្លាក់ខ្លួនមកដីដោយប្រើឆ័ត្រយោង។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦២ លោកស្រីត្រូវបានជ្រើសរើសជាមួយស្ត្រីបីនាក់ទៀត ដែលជាអ្នកលោតឆ័ត្រយោងដូចគ្នា និងស្ត្រីម្នាក់ទៀតដែលជាអ្នកបើកយន្តហោះ ដើម្បីចាប់ផ្តើមការហ្វឹកហាត់ឲ្យក្លាយទៅជាអវកាសយានិក។

ក្នុងឆ្នាំ១៩៦៣ លោកស្រី Tereshkova ត្រូវបានជ្រើសរើសឲ្យចូលរួមក្នុងបេសកម្មមួយនៃកម្មវិធីយាន Vostok ដោយមានការប្រើប្រាស់ យានអវកាស Vostok 5 និង Vostok 6។ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦៣ យាន Vostok5 ត្រូវបានបាញ់បង្ហោះឡើងទៅកាន់ទីអវកាស ដោយមានអវកាសយានិកលោក វ៉ាឡេរី ប៊ីកូវស្គី (Valeri Bykovsky) ជិះក្នុងនោះ។

ខណៈលោក Bykovsky កំពុងបន្តដំណើរគោចរជុំវិញផែនដី លោកស្រី Tereshkova ក៏ត្រូវបានបញ្ជូនឡើងទៅកាន់ទីអវកាសថែមទៀតដោយប្រើយាន Vostok 6 នៅថ្ងៃទី១៦ ខែមិថុនា គឺ២ថ្ងៃក្រោយលោក Bykovsky។ យានអវកាសទាំងពីរមានគន្លងធ្វើដំណើរផ្សេងៗពីគ្នា ប៉ុន្តែនៅត្រង់ចំណុចមួយ យានទាំងពីរបានមកស្ថិតនៅចម្ងាយជិត៥គីឡូម៉ែត្រពីគ្នា ដែលអាចអនុញ្ញាតឱ្យអវកាសយានិកទាំងពីររូបមានឱកាសភ្ជាប់ការទាក់ទងគ្នាបានមួយភ្លែត។

យានអវកាសរបស់លោកស្រី Tereshkova ត្រូវបានដឹកនាំធ្វើដំណើរដោយប្រព័ន្ធបញ្ជាស្វ័យប្រវត្តិ គឺលោកស្រីមិនបានបញ្ជាយានដោយ ផ្ទាល់ដៃទេ។ នៅថ្ងៃទី១៩ ខែមិថុនា គឺក្រោយចំណាយពេលជិត៣ថ្ងៃនៅក្នុងទីអវកាស យាន Vostok 6 បានចាប់ផ្តើមការត្រឡប់ចុះមក ផ្ទៃផែនដីវិញ។ លោកស្រី Tereshkova បានលោតឆ័ត្រចុះមកដល់ដីដោយសុវត្ថិភាព ក្រោយចាកចេញពីយាននៅកម្ពស់ជិត៧គីឡូម៉ែត្រ។ ចំណែកលោក Bykovsky ក៏បានចុះមកដោយសុវត្ថិភាពដែរនៅប៉ុន្មានម៉ោងក្រោយមក។

ក្រោយការធ្វើដំណើរជាប្រវត្តិសាស្ត្រនេះ លោកស្រី Valentina Tereshkova ទទួលបានពានរង្វាន់យ៉ាងខ្ពង់ខ្ពស់របស់ សហភាពសូវៀត។ នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ លោកស្រីបានរៀបការជាមួយលោក អាន់ឌ្រាន នីកូឡាយេវ (Andrian Nikolayev) ដែលជាអវកាសយានិកដូចគ្នា។ យ៉ាងណាក្តី មិនយូរប៉ុន្មានក្រោយមក អ្នកទាំងពីរក៏បានបែកផ្លូវគ្នាដោយបន្សល់ទុកកូនស្រីម្នាក់។

នៅឆ្នាំ១៩៦៦ លោកស្រី Tereshkova បានក្លាយជាសមាជិកសភារបស់សហភាពសូវៀត និងបានដើរតួនាទីជាអ្នកតំណាងរបស់សូវៀតប្រចាំអង្គការនិងព្រឹត្តិការណ៍អន្តរជាតិសម្រាប់ស្ត្រីជាច្រើនផងដែរ។ លោកស្រីមិនដែលធ្វើដំណើរទៅកាន់លំហអវកាសបន្តទៀតនោះឡើយ។ រហូតទាល់តែដល់ទសវត្សរ៍ឆ្នាំ១៩៨០ ទើបមានស្ត្រីអវកាសយានិកសូវៀតឡើងទៅកាន់ទីអវកាស ជាថ្មីម្តងទៀត។

កាលពីឆ្នាំ១៩៥០ និង១៩៦០ សហរដ្ឋអាមេរិកបានពិនិត្យលើស្ត្រីអ្នកបើកយន្តហោះមួយក្រុមផងដែរ ក្រោមគោលដៅចង់បង្វឹកពួកគេឲ្យក្លាយជាអវកាសយានិក ប៉ុន្តែក្រោយមកក៏បានសម្រេចចិត្តកម្រិតនូវសកម្មភាពហ្វឹកហាត់អស់ទាំងនេះសម្រាប់តែបុរសប៉ុណ្ណោះវិញ។ ស្ត្រីជនជាតិអាមេរិកដំបូងបំផុតដែលបានធ្វើដំណើរទៅក្នុងទីលំហអវកាសនោះគឺ លោកស្រី សលលី រ៉ាយ (Sally Ride) ដែលមានតួនាទីជាអ្នកជំនាញបេសកកម្ម នៅលើជើងហោះហើររបស់យានអវកាស ឆាលែញចឺ (Challenger) កាលពីឆ្នាំ១៩៨៣៕ *(អត្ថបទដកស្រង់ពីបណ្តាញសារព័ត៌មានហ្វ្រេសញ៉ីវ)*

# អាជីវកម្មសត្វកណ្ដុរ កំពុងពេញនិយមនៅលើទីផ្សារ ខណៈតម្រូវការច្រើន



*អត្ថបទ៖ អមរិទ្ធិ ដានុត*

ខេត្តបាត់ដំបង៖ «សត្វកណ្ដុរដែលខ្ញុំចិញ្ចឹមសព្វថ្ងៃនេះ នៅតែមានទីផ្សារល្អ តំលៃនៅថេរដដែល រីឯអតិថិជនទូរស័ព្ទមកខ្ញុំ កុម្ម៉ង់ទិញស្ទើររាល់ថ្ងៃ ឥឡូវខ្ញុំចិញ្ចឹមមិនទាន់អ្នកទិញទេ»។ នេះជាការអះអាងរបស់លោកម៉ុយ ចំរើន ម្ចាស់កសិដ្ឋានចិញ្ចឹមកណ្ដុរ ដែលមានទីតាំង នៅភូមិសួនស្លា ឃុំក្ដុលតាហែន ស្រុកបវេល។

លោក ម៉ុយ ចំរើន បានប្រាប់កោះសន្តិភាពថា ជិត០៣ឆ្នាំកន្លងមកហើយ ដែលលោកបង្កើតកសិដ្ឋានចិញ្ចឹមសត្វកណ្ដុរធ្វើជាអាជីវកម្ម។ គាត់និយាយថា អតិថិជនភាគច្រើនកុម្ម៉ង់ទិញតាមទូរសព្ទ យកទៅធ្វើម្ហូបជាលក្ខណៈគ្រួសារ និងទិញពូជយកទៅចិញ្ចឹម។ ចាប់តាំងពីលោកប្រកាសលក់លើទីផ្សារតាំងពីដំបូង រហូតមកដល់សព្វថ្ងៃនេះ តំលៃកណ្ដុរនៅថេរដដែល ។



បច្ចុប្បន្ន សត្វកណ្ដុរដែលលោកចិញ្ចឹម កើតមិនទាន់អ្នកទិញទេ (អត់មានកណ្ដុរលក់ឲ្យអតិថិជន) រីឯអតិថិជនរឹតតែទូរស័ព្ទសួរនាំមិនដាច់។ បើតាមមើលសកម្មភាពម្ចាស់កសិដ្ឋានចិញ្ចឹមកណ្ដុររូបនេះ ហាក់មិនសូវមានពេលទំនេរជជែកលែងអំពីការងារផ្សេងៗ ក្រៅតែពីនិយាយរឿងចិញ្ចឹមសត្វកណ្ដុររបស់គាត់ទេ។ ទូរស័ព្ទរបស់គាត់ឮសម្លេងរោទ៍មិនដាច់សោះ តែគាត់ក៏មិនឲ្យខកខានក្នុងលើកទទូលទូរស័ព្ទដែរ ។

លោក ម៉ុយ ចំរើន បានប្រាប់ដូច្នេះថា «នោះជាទូរស័ព្ទរបស់ម៉ូយៗ ដែលសួរនាំរកទិញកណ្ដុរ ឬ សួរនាំពីការចិញ្ចឹមកណ្ដុរ»។ គាត់និយាយថា «ការថែទាំសត្វកណ្ដុរមិនសូវជារវល់ប៉ុន្មានទេ តែខ្ញុំរវល់ខ្លាំងនឹងលើកទូរស័ព្ទស្វាគមន៍អ្នកកុម្ម៉ង់ទិញកណ្ដុរ ឬសួរនាំពីបច្ចេកទេសចិញ្ចឹមកណ្ដុរ ។ អធ្យាស្រ័យផង ដែលខ្ញុំរវល់លើកទូរស័ព្ទភ្ញៀវមិនបានជជែកគ្នាបានច្រើន» ។

ក្រោមដំបូលរោងប្រក់ស័ង្កសី មានបណ្ដោយប្រហែល២០ម៉ែត្រ គ្មានជញ្ជាំងទេ តែមានដាក់តម្រៀបផ្ទាំងថ្មបេតុងពីរជួរ មានកំពស់ជិតមួយម៉ែត្រ ជាបន្ទប់ៗ តូចៗបួនជ្រុងបិទគម្របជិត និង មានបំពាក់ដបទឹកផង ។ នោះជាបន្ទប់សម្រាប់ចិញ្ចឹមកណ្ដុរ ។ ម្ចាស់កសិដ្ឋាន លោក ម៉ុយ ចំរើន បានចាប់សត្វកណ្ដុរពូជលើកបង្ហាញ ហើយពន្យល់ថា «សត្វកណ្ដុរដែលខ្ញុំចិញ្ចឹមសព្វថ្ងៃនេះ មានពីរប្រភេទ គឺពូជកណ្ដុរប្រែង និងពូជកណ្ដុរឫស្សី ឬ ហៅអាអុន»។

លោកបានបញ្ជាក់ឱ្យដឹងថា៖ «ពូជកណ្ដុរប្រែងមានពីរពណ៌ គឺពណ៌ខ្មៅ និងពណ៌ស រីឯពូជកណ្ដុរឫស្សី ឬ អាអុន មានតែមួយពណ៌ តែខ្ញុំចិញ្ចឹមតិចជាងពូជកណ្ដុរប្រែង ហើយតំលៃក៏ខុសគ្នាច្រើនដែរ គឺអាអុនលក់ថ្លៃជាងកណ្ដុរប្រែង។ ពូជសត្វទាំងពីរនេះងាយចិញ្ចឹម ហើយងាយរកទីផ្សារបំផុត»។ បើនិយាយពីតំលៃនៃសត្វកណ្ដុរទាំងពីរប្រភេទនេះ ម្ចាស់កសិដ្ឋានរូបនេះបានប្រាប់ថា សត្វកណ្ដុរទាំងពីរប្រភេទនេះ លោកពុំមានដាក់លក់នៅតាមទីផ្សារទេ បើទោះជាមានអតិថិជនច្រើនកុម្ម៉ង់ទិញក្ដី ។

ម៉ូយភាគច្រើន ដែលកុម្ម៉ង់ទិញ គឺ «ទិញយកទៅធ្វើម្ហូបជាលក្ខណៈគ្រួសារ និងទិញពូជយកទៅចិញ្ចឹមបន្ត»។ គាត់ប្រាប់ថា កណ្ដុរដែលអតិថិជនទិញយកទៅហូប គឺតំលៃ២៥,០០០រៀល ក្នុង១គីឡូក្រាម តែបើទិញពូជយកទៅចិញ្ចឹម ក្នុង១ឈុត (មេ២ឈ្មោល១) តំលៃចន្លោះពី១០ម៉ឺនដល់ ១៥ម៉ឺនរៀល តាមទំហំតូច ឬធំ។

ដោយឡែកចំពោះពូជកណ្ដុរឫស្សីឬហៅអាអុនវិញ លោកមិនមានលក់សម្រាប់កាប់សាច់ទេ តែលក់ធ្វើពូជ តំលៃក្នុង០១គូ (មេ១ឈ្មោល១) ថ្លៃ ៣៨០ដុល្លារឯណោះ តែពេលនេះ លោកចិញ្ចឹមមិនទាន់តម្រូវការអ្នកទិញទេ ។ បើនិយាយពីអតិថិជនវិញ ម្ចាស់កសិដ្ឋានចិញ្ចឹមកណ្ដុរដ៏មមារញឹករូបនេះ បានបញ្ជាក់ថា «អតិថិជនដែលកុម្ម៉ង់ទិញកណ្ដុរខ្ញុំ មានស្ទើរគ្រប់ខេត្តក្រុង។ មួយថ្ងៃៗ ទូរស័ព្ទកុម្ម៉ង់ទិញមិនឈប់ឈរ ទាំងទិញទៅធ្វើម្ហូប ទាំងទិញទៅចិញ្ចឹម រីឯម៉ូយខ្លះសួរនាំពីវិធីចិញ្ចឹម ក្រោយពួកគេទិញពូជយកទៅចិញ្ចឹម»។

ប៉ុន្តែយ៉ាងណា បើតាមលោក ម៉ុយ ចំរើន បានបញ្ជាក់ថា «ពេលនេះ ខ្ញុំចិញ្ចឹមកណ្ដុរ កើតមិនទាន់អ្នកទិញទេ។ នៅក្នុងកសិដ្ឋានសល់តែពូជប៉ុណ្ណោះ ដែលកំពុងបង្កើតកូនបន្ត» ៕

*(ប្រភព៖ សារព័ត៌មានកោះសន្តិភាព)*

# ចិញ្ចឹមឃ្មុំរកចំណូលបានច្រើន ខណៈមានតម្រូវការទីផ្សារ

*អត្ថបទ៖ ផល សុផានិត*

ក្រៅពីការប្រកបរបរកសិកម្មដូចជា ការធ្វើចម្ការដាំដុះទុរេន សារ៉ម៉ាវ មង្ឃុត និងតាងែននោះ ប្រជាសហគមន៍ដែលរស់នៅក្នុងសហគមន៍តាខេះមានជ័យ ក្នុងស្រុកសំឡូត ខេត្តបាត់ដំបង បាននាំគ្នាចិញ្ចឹមឃ្មុំ ដើម្បីរកប្រាក់ចំណូលបន្ថែម និងជួយលើកកម្ពស់ជីវភាពគ្រួសារ ឱ្យកាន់តែប្រសើរ ខណៈផលិតផលទឹកឃ្មុំនេះបានផ្ដល់ផលល្អ និងជាមុខរបរមួយមានទីផ្សារល្អសម្រាប់ពួកគាត់នាពេលបច្ចុប្បន្ន។

ការនាំគ្នាចិញ្ចឹមឃ្មុំរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍តាខេះមានជ័យនេះ ដោយមានការជួយបង្ហាត់បង្រៀនពីមូលនិធិម៉ាដក្បជូលីភីត (MJP) ដែលបង្កើតឡើងដោយតារាហូលីវូដ អេនជេលីណា ជូលី នៅឆ្នាំ២០០៣ និងពង្រីកសាខានៅកម្ពុជា ក្នុងឆ្នាំ២០០៦ ដែលបានជួយបណ្ដុះបណ្ដាលដល់ប្រជាសហគមន៍នៅក្នុងស្រុកសំឡូត ខេត្តបាត់ដំបង ឱ្យចេះពីវិធីចិញ្ចឹមឃ្មុំ ការផលិតយកទឹកឃ្មុំសម្រាប់លក់ ដើម្បីបង្កើនប្រាក់ចំណូលក្នុងជីវភាពគ្រួសារដែលរស់នៅក្នុងតំបន់នោះ។

បច្ចុប្បន្ន ប្រជាសហគមន៍ដែលបានចិញ្ចឹមឃ្មុំ សរុបជាង៣០គ្រួសារ ហើយមានធុងដែលជាសំបុកសត្វឃ្មុំសម្រាប់ចិញ្ចឹមនោះ ប្រមាណត្រឹម១០០ធុងប៉ុណ្ណោះ។ ចំពោះទឹកឃ្មុំដែលសហគមន៍ប្រមូលផលបានគឺមានទីផ្សារច្រើន ដោយសារទឹកឃ្មុំសុទ្ធល្អ គ្មានការលួចបន្លំ ឬលាយលំអ៊ីនោះឡើយ ជាពិសេសនោះការផលិតទឹកឃ្មុំគឺមានលេខកូដសម្គាល់របស់សហគមន៍តែម្ដង។

អ្នកស្រី ជ័យ រ៉ង គឺជាអ្នកចិញ្ចឹមឃ្មុំម្នាក់ដែលរស់នៅក្នុងសហគមន៍តាខេះមានជ័យ ក្នុងស្រុកសំឡូតបាននិយាយថា អ្នកស្រីបានចាប់ផ្ដើមចិញ្ចឹមឃ្មុំនេះ គឺតាំងពីឆ្នាំ២០១៨មកម្ល៉េះ។ អ្នកស្រីបន្តថា ការចិញ្ចឹម ឃ្មុំនេះបានធ្វើឱ្យជីវភាពគ្រួសារអ្នកស្រីអាចជួយដោះស្រាយបានមួយផ្នែកផងដែរដូចជាទិញសម្ភារប្រើប្រាស់ ផ្គត់ផ្គង់ការសិក្សារបស់កូន និងបង់ការប្រាក់ធនាគារ ជាដើម។

អ្នកស្រី ជ័យ រ៉ង ថា ៖ «មុខរបរចិញ្ចឹមឃ្មុំនេះជាមុខរបរបន្ទាប់សន្សំទី២ ហើយខ្ញុំជាស្ត្រីអាចធ្វើទៅបានព្រោះថា ការដឹកធុងផ្លាស់ប្ដូរទីតាំង និងរៀបចំដាក់តាមចម្ការហើយ ពេលបានផល វាអាចជួយកាត់បន្ថយការចាយវាយក្នុងជីវភាពប្រចាំថ្ងៃ ជួយឱ្យកូនរៀន ទិញនេះទិញនោះ និងបង់ធនាគារ ជាដើម»។

អ្នកស្រីបានថ្លែងឱ្យដឹងថា ប្រសិន បើឃុំមានផ្កាសម្រាប់ស្រូបល្អ ឬច្រើននោះក្នុងរយៈពេលកន្លះខែអាចប្រមូលបានម្ដង។ ដោយក្នុង១០ធុងឬសំបុកដែលដាក់ឱ្យឃ្មុំនោះ ប្រមូលបាន២កានដោយក្នុងមួយកានស្មើនឹង ២៥លីត្រទឹកឃ្មុំ ហើយទឹកឃ្មុំលក់បាន១លីត្រ តម្លៃ៧ម៉ឺនរៀល។

លោក ឌុក ម៉េង ប្រធានសហគមន៍ព្រៃឈើភូមិកញ្ជាំង ស្រុកសំឡូត ខេត្តបាត់ដំ បងបានបញ្ជាក់ឱ្យដឹងថា សហគមន៍មានផ្ទៃដីទំហំ ៤០០ ហិកតា ហើយប្រជាសហគមន៍ចាប់ផ្ដើមចិញ្ចឹមឃ្មុំតាំងតែពីឆ្នាំ២០១៨មកដែលការចិញ្ចឹមសត្វឃ្មុំនេះ បានផ្ដល់នូវអត្ថប្រយោជន៍ដល់សហគមន៍ ពីព្រោះថាក្រៅពីជួយបង្កាត់កេសរផ្លែឈើឱ្យជាប់ និងកាន់បានផ្លែច្រើន ហើយទឹកឃ្មុំក៏អាចលក់រកប្រាក់កម្រៃសម្រាប់ជួយលើកស្ទួយជីវភាពគ្រួសារទៀតផង។

លោក ឌុក ម៉េង ថា ៖ «កាលពីមុនមកធុងដែលជាសំបុកសត្វឃ្មុំមានប្រមាណ១៨០ធុង តែនៅពេលបច្ចុប្បន្ននៅសល់ត្រឹម ៨០ធុង ឬ១០០ធុង ដោយសាររដូវក្ដៅទើបកន្លងផុតទៅ។ ឃ្មុំទាំងនេះ ជាឃ្មុំចិញ្ចឹម យកពូជបង្កាត់មកពីប្រទេសអឺរ៉ុប។ ពីដើមឡើយដោយសារមូលនិធិ ម៉ាដក្បជូលីភីត បានបង្ហាត់បង្រៀនក្នុងការចិញ្ចឹមសត្វឃ្មុំឱ្យស្គាល់ពីតម្លៃនៃការចិញ្ចឹមឃ្មុំ។ នៅពេលចិញ្ចឹមក៏ចេះតែចង់ ព្រោះជោគជ័យក៏រួមគ្នាចិញ្ចឹមរហូតមកដល់ពេលបច្ចុប្បន្នតែម្ដង»។

ពាក់ព័ន្ធនឹងការចិញ្ចឹមឃ្មុំនេះដែរ លោក មិល សាម៉េត ប្រធានគ្រប់គ្រងកម្មវិធីកសិកម្ម និងការចិញ្ចឹមឃ្មុំ នៃមូលនិធិម៉ាដក្បចូលីភីត ដែលមានទីតាំងស្ថិតនៅស្រុកសំឡូត ខេត្តបាត់ដំបង បានគូសបញ្ជាក់ថា កម្មវិធីចិញ្ចឹមឃ្មុំ នេះគឺផ្ដល់ផលប្រយោជន៍ដល់ប្រជាសហគមន៍ច្រើនណាស់ ដោយពួកគាត់ទទួលបានផលប្រយោជន៍ដោយផ្ទាល់និងប្រយោលពីការចិញ្ចឹមឃ្មុំ៕

# គ្រីស្តបរិស័ទអ្នកលឿងធ្វើបូជនីយេសក៏កន្លែងមរណបុគ្គល

*អត្ថបទ៖ ម៉េង ភីឡុង*

ក្នុងអំឡុងខួប១៦០ឆ្នាំនៃការកកើត ព្រះសហគមន៍បាណាម អ្នកលឿង លោកបូជាចារ្យ សេរ៉ាល វូសាំង បានណែនាំគ្រីស្តបរិស័ទចំនួន១៣នាក់ បានធ្វើដំណើរបូជនីយេសក៏ ទៅកាន់ទីកន្លែងមរណបុគ្គលនៃព្រះសហកមន៍អ្នកលឿងមួយចំនួនដែលបានទទួលមរណភាពក្នុងអំឡុងរបបប្រល័យពូជសាសន៍ប៉ុលពត នៅតាមតំបន់ខ្លះក្នុងប្រទេសកម្ពុជា។



ដំណើរនេះបានចាប់ផ្តើមពីព្រះសហគមន៍អ្នកលឿង ឆ្ពោះទៅទឹកដីតាំងគោកក្នុងខេត្តកំពង់ធំ បន្ទាប់មកទៅព្រះសហគមន៍ក្តុលលើក្នុងខេត្តត្បូងឃ្មុំ ចុងបញ្ចប់គឺដល់ព្រះសហគមន៍ក្រចេះ ក្នុងភូមិភាគកំពង់ចាម ដើម្បីស្គាល់អំពីជីវិតរបស់លោក ដាមីយ៉ាំង ដាំងង៉ុក អាំង និងលោក សិលា ឡេ ធឿង ឌុង ជាអ្នកបួសដែលមានកំណើតនៅព្រះសហគមន៍បាណាម អ្នកលឿង។ កម្មវិធីបូជនីយេសក៏នេះ ធ្វើឡើងកាលពីថ្ងៃទី០៣-០៤ ខែតុលាកន្លងទៅ។



ក្នុងដំណើរនោះ អ្នកបូជនីយេសក៏បានស្តាប់សក្ខីភាពពីគ្រីស្តបរិស័ទដែលស្គាល់លោកទាំងពីរ អធិដ្ឋាននិងថ្វាយអភិបូជារួមជាមួយគ្នា ដោយប្រើចានព្រះកាយ និងពែងព្រះលោហិត ដែលលោកបូជាចារ្យ សិលា ឡេ ធឿង ឌុង បានទទួលនៅថ្ងៃគាត់បានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅឆ្នាំ១៩៦៩ រហូតដល់ឥឡូវនេះ គឺមានអាយុកាលជាង៥០ឆ្នាំហើយ ដែលត្រូវបានក្រុមគ្រួសាររក្សាទុករហូតដល់សព្វថ្ងៃនៅប្រទេសវៀតណាម។



អ្នកស្រី ឡេ ធី មី ង៉ៀត ជាប្អូនស្រីបង្កើតរបស់លោកបូជាចារ្យ សិលា ឡេ ធឿង ឌុង បានមកចូលរួមកម្មវិធីនេះឲ្យដឹងថា លោកបូជាចារ្យឌុង និងបងប្រុសដាមីញ៉ាំង បានរស់នៅនិងរងទុក្ខលំបាកជាច្រើន ហើយពេលធ្វើបូជនីយេសក៏ នាំឲ្យគាត់មានអារម្មណ៍រំភើបយ៉ាងខ្លាំង ដោយឃើញថា ព្រះសហគមន៍បានយកចិត្តទុកដាក់ដល់អស់អ្នកដែលបានបូជាជីវិតដោយក្តីស្រឡាញ់សម្រាប់ព្រះជាម្ចាស់។

អ្នកស្រីបន្តថា ពេលគាត់បានមកដល់ខេត្តក្រចេះ កន្លែងដែលបងប្រុសរបស់គាត់ត្រូវគេសម្លាប់ «ខ្ញុំពិតជាឈឺចិត្តខ្លាំងណាស់ ដោយនឹកឃើញពីការឈឺចាប់ដែលលោកឪពុក ឌុង ទទួលនៅពេលនោះ»។





អ្នកស្រីបន្ថែមថា ទោះយ៉ាងណាគាត់សង្ឃឹមថា តាមរយៈអស់អ្នកដែលបានបូជាជីវិតក្នុងសម័យសង្គ្រាមនោះ ជួយឲ្យព្រះសហគមន៍នៅប្រទេសកម្ពុជាកាន់តែរីកចម្រើនទៅមុខទៀត។

អ្នកស្រីឡេ ធី មី ង៉ៀត ធ្លាប់រស់នៅក្នុងប្រទេសកម្ពុជានៅព្រះសហគមន៍បាណាម អ្នកលឿង ហើយបានចាកចេញទៅរស់នៅប្រទេសវៀតណាមក្នុងអំឡុងរបបប្រល័យពូជសាសន៍ប៉ុលពត។

ក្នុងថ្ងៃធ្វើដំណើរទៅដល់ព្រះសហគមន៍ក្តុលលើ លោកអភិបាល សិលា សួន ហង្សលី អភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម បានថ្វាយអភិបូជានៅទីនោះ។

លោកអភិបាលមានប្រសាសន៍ថា អត្ថបទព្រះគម្ពីរដំណឹងល្អថ្ងៃនេះ ស្តីអំពីកូនចៀមក្នុងហ្វូងចចក ដែលស្របនឹងជីវិតរបស់លោកបូជាចារ្យសិលា ឡេ ធឿង ឌុង ដែលបានបូជាជីវិតក្នុងសម័យសង្គ្រាម។ លោកមិនព្រមទៅវៀតណាម តែបានជ្រើសរើសរស់នៅជាមួយគ្រីស្តបរិស័ទនិងប្រជាជននៅកម្ពុជា។

លោកឌុងមានប្រសាសន៍ថា «បើកន្លែងនេះនៅមានគ្រីស្តបរិស័ទ ខ្ញុំត្រូវនៅជាមួយគ្រីស្តបរិស័ទ ដើម្បីលើកទឹកចិត្តគេ ថែរក្សាគេ និងណែនាំគេកុំឲ្យគេបាត់បង់ជំនឿ» នេះជាការបញ្ជាក់របស់លោកអភិបាល។

លោកអភិបាលលើបន្ថែមថា លោក ឌុង ជាគំរូសម្រាប់អស់សាសនាទូតទាំងឡាយ ដែលចង់ប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ក្នុងពិភពលោកនេះ លោកជួយឲ្យយើងដឹងថាជំនឿសំខាន់ណាស់ រាល់ពេលយើងជួបការលំបាកក្នុងជីវិត សូមកុំលះបង់ជំនឿ។

លោកអភិបាលបន្តថា «សូមឲ្យការបូជាជីវិតរបស់លោកឪពុកឌុង ជួយឲ្យយើងមានជំនឿកាន់តែរឹងមាំឡើង និងព្យាយាមរួបរួមគ្នាកសាងសន្តិភាព និងព្យាយាមប្រកាកដំណឹងល្អ ឲ្យព្រះសហគមន៍យើងកាន់តែរីកចម្រើន»។

ព្រះសហគមន៍បាណាម អ្នកលឿង បានកកើតឡើងនៅឆ្នាំ១៨៦២ ដោយគ្រីស្តបរិស័ទពីគូឡៅទៃ (Cu lao tay) នៅប្រទេសវៀតណាម ប្រមាណ១០០០នាក់ បានរត់ភៀសខ្លួនពីការធ្វើទុក្ខបុកម្នេញពីព្រះចៅអាណ្ណាមមកនៅកម្ពុជា។

ក្នុងឯកសារស្រាវជ្រាវពីប្រវត្តិព្រះសហគមន៍នៅអ្នកលឿងបានរកឃើញថា បងប្រុស ដាមីយ៉ាំង ដាំង ង៉ុក អាំង (Đamien Dang Ngoc An) និងលោកបូជាចារ្យ សិលា ឡេ ធឿង ឌុង ( Le Thuong Dung) ជាបូជាចារ្យក្នុងភូមិភាគកំពង់ចាម រស់នៅនៅព្រះសហគមន៍បាណាម ហើយនៅសម័យសង្គ្រាម ក្នុងអំឡុងពេល ១៩៧០ ដល់ឆ្នាំ១៩៧៥ គ្រីស្តបរិស័ទនៅបាណាម (អ្នកលឿង) បានរត់ភៀសខ្លួនទៅប្រទេសវៀតណាមវិញ តែលោកទាំងពីរបានសម្រេចចិត្តបន្តនៅស្រុកខ្មែរ ហើយបានស្លាប់នៅក្នុងអំឡុងពេលនោះ។



លោកសិលា ត្រាំង វ៉ាំង ឡាំ ជាប្រធានគណៈកម្មការព្រះសហគមន៍អ្នកលឿង បានប្រាប់ថា ដោយសារជំនឿ សេចក្តីក្លាហាន និងសេចក្តីស្រឡាញ់របស់លោកពុកឌុង បានក្លាយជាពន្លឺបំភ្លឺដល់គ្រីស្តបរិស័ទយើងក្នុងសម័យនេះ កាន់តែមានជំនឿមាំមួនឡើង។

សូមបញ្ជាក់ តាម លោកបូជាចារ្យ សេរ៉ាល វូសាំង បានឲ្យដឹងថា ព្រះសហគមន៍អ្នកលឿង បានកំពុងរៀបចំប្រវត្តិព្រះសហគមន៍នេះ និងប្រវត្តិរបស់លោកបូជាចារ្យនិងបងប្រុសទាំងពីរ។ និងកំពុងស្រាវជ្រាវរកសក្ខីភាពពីគ្រីស្តបរិស័ទមួយចំនួន ដោយយោងជាមួយឯកសារជាច្រើនជាភាសាបារាំង។

លោកបន្ថែមថា រហូតដល់ពេលនេះ ឯកសារនោះរៀបចំជិតបានរួចរាល់ហើយ ហើយកំពុងកែសម្រួលព័ត៌មានខ្លះៗនិងបកប្រែជាភាសាខ្មែរ៕

# គ្រីស្តបរិស័ទសាទរទទួលបូជាចារ្យថ្មីបីរូប

*អត្ថបទ៖ ចាន់ម៉ានុត*

គ្រីស្តបរិស័ទជិត៣០០០នាក់បានមកចូលរួមពិធីតែងតាំងលោកបូជាចារ្យភូមិភាគចំនួនបីអង្គ គឺលោក យ៉ូហាន បាទីស្តវី សំណាង លោក ប៉ូល វិនកាន់ និងលោក អន់តូនី ថៃ រតនៈ(ប៊ុនលី) នៅមជ្ឈមណ្ឌលភូមិភាគភ្នំពេញ ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកញ្ញាកន្លងទៅ។

លោកទាំងបីទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្រោមអធិបតីភាព លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកកម្ពុជា រួមនិងលោកអភិបាល ភូមិភាគបាត់ដំបងនិងកំពង់ចាម ដោយមានលោកបូជាចារ្យទាំងបីភូមិភាគចូលរួមយ៉ាងកុះករ។

បូជាចារ្យនៅក្នុងព្រះសហគមន៍កាតូលិក គឺជាតំណាងរបស់ព្រះយេស៊ូដើម្បីធ្វើពិធីថ្វាយសក្ការបូជាទៅព្រះជាម្ចាស់ដែលគ្រីស្តបរិស័ទហៅថា «អភិបូជា»។ អស់លោកជាបូជាចារ្យ ត្រូវរស់នៅលីវអស់មួយជីវិត ដោយបម្រើព្រះសហគមន៍តាមរយៈអគ្គសញ្ញានានា ជួយណែនាំគ្រីស្តបរិស័ទឲ្យរស់នៅតាមមាគ៌ារបស់ព្រះជាម្ចាស់។ ពួកលោកមានពាក្យសច្ចាបី គឺរស់នៅរក្សាព្រហ្មចារីធម៌ ស្តាប់បង្គាប់ និងរស់នៅបែបក្រីក្រ។

លោកអភិបាល សិលា សួន ហង្សលី ជាអភិបាលជនជាតិខ្មែរនៃភូមិភាគកំពង់ចាម បានមានប្រសាសន៍ថា នៅពេលព្រះសហគមន៍កម្ពុជាមានបូជាចារ្យជាតិខ្មែរក្នុងស្រុកកាន់តែច្រើន ជាការលើកទឹកចិត្តមួយសម្រាប់គ្រីស្តបរិស័ទឱ្យយល់ថា ព្រះសហគមន៍របស់យើងកាន់តែរីកចម្រើន ដើម្បីជួយណែនាំព្រះសហគមន៍និងណែនាំឱ្យជំនឿរបស់គ្រីស្តបរិស័ទកាន់តែរឹងមាំដែរ។ ហើយនេះបង្ហាញអំពីរបៀបដែលព្រះជាម្ចាស់កំពុងតែធ្វើការនៅក្នុងព្រះសហគមន៍របស់យើងនឹងបង្ហាញអំពីវត្តមានរបស់ព្រះអង្គ។

លោកថា«សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំពិតជាអរព្រះគុណព្រះជាម្ចាស់ ហើយនិងអរគុណសម្រាប់ក្រុមគ្រួសាររបស់លោកបូជាចារ្យទាំងបីនាក់ ដែលបានអនុញ្ញាតឱ្យកូនថ្វាយខ្លួនទៅព្រះជាម្ចាស់ ហើយក្លាយខ្លួនជាបូជាចារ្យ។»

ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានកកើតឡើងជិត៥០០ឆ្នាំមកហើយ នេះបើយោងទៅតាមឯកសារប្រវត្តិសាស្ត្រព្រះសហគមន៍របស់លោកបូជាចារ្យប្រ្វង់ស័រ ប៉ុងសូដស៍។ ព្រះសហគមន៍នេះបានរីកចម្រើនបន្តិចម្តងៗ ហើយបានរងការបំផ្លាញ ដោយសង្គ្រាមរាប់មិនអស់ និងបានរងគ្រោះរួមជាមួយសាសនាឯទៀត និងប្រជាជនកម្ពុជាក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត ដោយបានសម្លាប់មនុស្សជិត២លាននាក់ ក្នុងនោះរួមទាំងលោកអភិបាលជាតិខ្មែរ យ៉ូសែប ឆ្មារសាឡាស់ អស់លោកបូជាចារ្យ បព្វជិត-ជិតានិងគ្រីស្តបរិស័ទមួយចំនួនធំ។

ក្រោយមកព្រះសហគមន៍បានកកើតឡើងវិញ តាមរយៈសាសនទូតក្រៅប្រទេស បានរួមគ្នាខិតខំប្រឹងប្រែងប្រកាសដំណឹងល្អ ហើយបានជ្រោមជ្រែងឲ្យមានបូជាចារ្យក្នុងស្រុកកើតឡើង។ បច្ចុប្បន្ននេះ ព្រះសហគមន៍កម្ពុជាដែលមានគ្រីស្តបរិស័ទជាង២ម៉ឺននាក់ មានបូជាចារ្យភូមិភាគចំនួន១៣អង្គ និងបព្វជិតចំនួន១អង្គ។

ក្នុងនាមជាបូជាចារ្យខ្មែរមួយរូប លោក ផាន បូរី ជាបូជាចារ្យទទួលខុសត្រូវនៅព្រះវិហារសន្តយ៉ាកុប(មណ្ឌលគិរី)នៃភូមិភាគកំពង់ចាម បានមានប្រសាសន៍ថា លោកពិតជាមានអំណរសប្បាយព្រោះជាសញ្ញាមួយដែលបង្ហាញថា «ព្រះសហគមន៍កម្ពុជាកំពុងតែធ្វើដំណើរទៅមុខ កំពុងតែអភិវឌ្ឍន៍និងកំពុងតែឈានជើងចូលក្នុងទឹកដីនៃការប្រកាសដំណឹងល្អនៅក្នុងប្រទេសកម្ពុជា។»

លោកបូជាចារ្យបូរី បន្ថែមថា ការទទួលបានលោកបូជាចារ្យថ្មីនេះ ជាសក្ខីភាពសម្រាប់យុវជនឱ្យចេះឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយហ៊ានឆ្លើយថាបាទឬចាស និងត្រូវសុខចិត្តលះបង់អ្វីៗជាច្រើនដែលខ្លួនចូលចិត្តធ្វើនៅសង្គម ដើម្បីនៅជាមួយព្រះយេស៊ូ ដោយសារសេចក្តីស្រលាញ់ចំពោះព្រះយេស៊ូ ទើបយើងសុខចិត្តថ្វាយខ្លួនទៅព្រះជាម្ចាស់។

ជាមួយគ្នានេះ លោក ឯម សារ៉េត ជាគ្រីស្តបរិស័ទមកពីព្រះសហគមន៍ជុំគិរីនៃមណ្ឌលសកម្មភាពកំពត ប្រាប់ថា គាត់មានមោទនភាពខ្លាំង ដែលមានជនជាតិខ្មែរស្ម័គ្រចិត្តលះបង់ជីវិតដើម្បីបម្រើព្រះសហគមន៍របស់ខ្លួន។









លោកសារ៉េត បន្តថា លោកមានបំណងចង់ថ្វាយកូនរបស់ខ្លួនដើម្បីបម្រើព្រះសហគមន៍ដូចលោកបូជាចារ្យដែរ។ លោកឲ្យដឹងថា « ខ្ញុំនឹងអធិដ្ឋានហើយជម្រុញលើកទឹកចិត្តពួកគាត់ ប្រសិនបើពួកគាត់ជ្រើសរើសផ្លូវជីវិតជាអ្នកបួស ខ្ញុំក៏សប្បាយហើយខ្ញុំក៏លះបង់ឱ្យតែពួកគាត់អាចបម្រើព្រះសហគមន៍ និងបម្រើព្រះជាម្ចាស់។»

មុនពេលបិទបញ្ចប់កម្មវិធីលោកអភិបាលអូលីវីយេ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានចាត់លោក




វី សំណាង ទៅបម្រើការងារនៅមណ្ឌលសកម្មភាពភ្នំពេញខាងជើង និងធ្វើជាជំនួយការរបស់លោក រីឯលោក ប៉ូល វិនកាន់ ទៅបម្រើការងារនៅមណ្ឌលសកម្មភាពតាកែវ និង លោក ថៃ រតនៈ(ប៊ុនលី) ទៅបម្រើនៅមណ្ឌលសកម្មភាពកំពតកែប៕

# លោកអភិបាលអូលីវីយេ លើកពីគំរូ៦ចំណុច របស់សន្តហ្វ្រង់ស៊ីស្កូអាស៊ីស៊ី

*អត្ថបទ៖ សួន ស្រីហ្គេចដាលីស*

ក្នុងឱកាសបុណ្យរំលឹកសន្តហ្វ្រង់ស៊ីស្កូអាស៊ីស៊ីកាលពីថ្ងៃទី៤ ខែតុលានេះ លោកអភិបាលបានដាស់តឿនឱ្យពិចារណាអំពី គម្រោងការរបស់ព្រះយេស៊ូដែលមានសម្រាប់ជីវិតគ្រីស្តបរិស័ទ តាមរយៈបទពិសោធជីវិតនៃជំនឿរបស់សន្តហ្វ្រង់ស៊ីស្កូ។



សន្តហ្វ្រង់ស៊ីស្កូ មានវត្តមាននៅក្នុងពិភពលោកនេះក្នុងឆ្នាំ១២០០ ត្រូវនឹង ៨០០ឆ្នាំមុនគឺ លោកមានទស្សនៈបង្កើតពិភពថ្មីតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយណែនាំឱ្យមនុស្សមានរបៀបរស់នៅថ្មីក្នុងសង្គម ដើម្បីទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលជិតមកដល់។

ថ្លែងក្នុងធម្មទេសនា នៅព្រះវិហារសន្តយ៉ូសែប ទួលក្រសាំង លោកអភិបាលអូលីវីយេ ជ្មិតហាស្លេ ណែនាំឲ្យគ្រីស្តបរិស័ទ យកគំរូសន្តហ្វ្រង់ស៊ីស្កូចំនួន៦ចំណុចសំខាន់ៗគឺ ទី១ ត្រូវចេះស្តាប់ព្រះយេស៊ូដោយអធិដ្ឋាននៅមុខឈើឆ្កាងព្រះយេស៊ូដែលអាចរកឃើញវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់ខ្លួន។ ទី២ ត្រូវដាក់ចិត្តជាអ្នកក្រខ្សត់ទើបមានសុភមង្គល ដូចសន្តហ្វ្រង់ស៊ីស្កូ ដែលយកភាពក្រីក្រធ្វើជាប្រពន្ធរស់នៅជាមួយមនុស្សដែលគាត់ជួបនៅតាមផ្លូវ។

ទី៣ បង្កើតក្រុមដើម្បីសហការ និងជួយគ្នាធ្វើដំណើរជាមួយគ្នា ក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ ទី៤ ត្រូវមានចិត្តប្រណីសន្ដោស មេត្តាករុណាដោយបម្រើអ្នកជំងឺ អ្នកតូចតាចក្រីក្រក្នុងសង្គម ជាពិសេសអ្នកដែលគេបោះបង់ចោលនិងសង្គមមិនរាប់រកជាដើម។ ទី៥ ត្រូវចេះស្រឡាញ់ស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅលើផែនដី ដោយគោរពនិងថែរក្សា។ និងទី៦ ចេះទំនាក់ទំនងជាមួយអ្នកមានសាសនាផ្សេងៗដោយចិត្តស្រឡាញ់ បម្រើ និងកសាងសុខសន្តិភាព ដោយចេះយល់ចិត្តគ្នាទៅវិញទៅមកនឹងធ្វើឱ្យសង្គមមានសេចក្តីសុខ។



នៅព្រះវិហារសន្តយ៉ូសែប ក្នុងភូមិទួលក្រសាំង សង្កាត់កោខ្ពស់ ក្រុងតាខ្មៅ បច្ចុប្បន្ន មានក្រុមគ្រួសារសន្តហ្វ្រង់ស៊ីស្កូអាស៊ីស៊ី កំពុងបម្រើការងារនៅតំបន់នោះ ដោយមានកម្មវិធីអប់រំជំនឿ និងវិស័យអប់រំចំណេះទូទៅ។ ក្រុមគ្រួសារនេះ បានចូលមកបម្រើព្រះសហគមន៍ប្រទេសកម្ពុជាចាប់ពីឆ្នាំ២០១០ ដោយមានសមាជិក៧នាក់ ក្នុងនោះមានលោកបូជាចារ្យ១នាក់ ឧបដ្ឋាក១នាក់ និងបងប្រុស៥នាក់។



តេរេសា ងួន ចរិយា ជាគ្រីស្តបរិស័ទក្នុងតំបន់បានឱ្យដឹងថា វត្តមានរបស់ក្រុមសន្តហ្វ្រង់ស៊ីស្កូនៅកម្ពុជានេះ ជាពិសេសក្នុងភូមិរបស់គាត់បានបង្កើតឲ្យមានសាលាមត្តេយ្យ សាលាបឋមសម្រាប់កុមារក្នុងភូមិ កសាងអាគារព្រះវិហារ។

ចរិយាបន្ថែមថា ក្រុមសន្តហ្វ្រង់ស៊ីស្កូជួយបង្រៀនយុវជនឲ្យចេះភ្លេង ចម្រៀងនិងណែនាំយុវជនឲ្យចេះស្រឡាញ់ដទៃ និងបង្កើតសកម្មភាពសប្បុរសធម៌នានា។

តេរេសា ងួន ចរិយា ថ្លែងថា៖ «ពួកគាត់បានផ្តល់ឱកាសឱ្យពួកខ្ញុំបានចូលរួមជួយអ្នកក្រីក្រនៅក្នុងភូមិ ក៏ដូចជាក្មេងៗនិងចាស់ជរាផងដែរ»៕

# ជំទង់ភូមិភាគភ្នំពេញឈ្វេងយល់ពីអាហារនិងប្រកួតស្នាដៃអាហារ

*អត្ថបទ៖ សួន ស្រីហ្គេចដាលីស*

ក្រុមជំទង់ចំនួន១៧០នាក់ ក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ បានចូលរួមសិក្សានិងប្រឡងប្រជែងគ្នា បង្កើតស្នាដៃធ្វើម្ហូបអាហារកាលពីថ្ងៃទី ២៩ ដល់ថ្ងៃ ទី១ ខែតុលា នៅមជ្ឈមណ្ឌលភូមិភាគភ្នំពេញ នារាជធានីភ្នំពេញ។





លោកស៊ាន់ សារឿន ជាប្រធានការិយាល័យកុមារជំទង់និងយុវជននៃភូមិភាគភ្នំពេញ ដែលបានរៀបចំកម្មវិធីនេះឡើងបានឱ្យដឹងថា កម្មវិធីនេះរៀបចំឡើងរវាង៣ឆ្នាំម្តង ដែលមានប្រធានបទបីសំខាន់ៗរិលជុំ គឺស្នាដៃខ្ញុំ ទេពកោសល្យរបស់ជំទង់ និង ជំទង់ចូលរួមក្នុងបរិស្ថាន។

ក្នុងឆ្នាំនេះ មានប្រធានបទគឺ ស្នាដៃម្ហូបខ្ញុំ ដែលឱ្យជំទង់ទាំងអស់ចាប់អារម្មណ៍ពីសមត្ថភាពទេពកោសល្យ និងស្នាដៃម្ហូប ការងារជាក្រុមដោយចេះសហការគ្នានិងបង្ហាញជំនឿនិងសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ។

លោកសារឿនបន្ថែមថា ក្រៅពីបង្ហាញស្នាដៃការិយាល័យក៏បាននាំជំទង់ឱ្យផ្សារភ្ជាប់ជាមួយផ្លូវវិញ្ញាណ ដោយជួយឱ្យគាត់ចូលរួមជាមួយព្រះសហគមន៍តាមរយៈការអធិដ្ឋាន ចូលរួមអភិបូជា និងចែករំលែកបទពិសោធរវាងគ្នានិងគ្នា។

កម្មវិធីនេះ មានជំទង់ចូលរួមពីអាយុ១៣ដល់១៧ឆ្នាំ មកពីមណ្ឌលសកម្មភាពចំនួន៨ របស់ព្រះសហគមន៍ភូមិភាគភ្នំពេញ។ ក្នុងរយៈពេល៣ថ្ងៃនេះ ពួកគាត់សិក្សាអំពីអត្ថប្រយោជន៍នៃម្ហូបអាហារសម្រាប់ប្រាជ្ញាស្មារតីនិងកម្លាំងចិត្តរបស់ជំទង់ ផលវិបាកនៃអាហារបំផ្លាញរាងកាយ។ នេះបើតាមអ្នកស្រី នៅ ម៉ាលីន អ្នកទទួលសុខត្រូវផ្នែក ជំទង់។

ម៉ាលីនបានធ្វើបទបង្ហាញដល់អ្នកចូលរួមពីគុណតម្លៃនិងអត្ថប្រយោជន៍អាហារ ៣ក្រុម មានអាហារថាមពល អាហារការពារ និងអាហារសាងសង់។ អ្នកស្រីម៉ាលីនក៏បានលើកពីសារជាតុដែលរាងកាយត្រូវការពីអាហារ ទាំងរបៀបទទួលអាហារឱ្យបានត្រឹមត្រូវនិងមានអនាម័យផងដែរ។

អ្នកស្រីបន្ថែមថា កម្មវិធីនេះ ក៏បង្រៀនឲ្យជំទង់ទាំងអស់ដឹងពីរបៀបនិងគ្រឿងផ្សំនៃការធ្វើម្ហូបនីមួយៗ ដើម្បីអនុវត្តសម្រាប់ខ្លួនគាត់នៅផ្ទះ។ ក្នុងនោះដែរ ពួកគាត់ត្រូវបែងចែកជាក្រុមៗ ជ្រើសរើសមុខម្ហូបដើម្បីយកមកប្រកួតប្រជែងទទួលជ័យលាភី។

ជំទង់ក្នុងវ័យ១៦ឆ្នាំមកពីព្រះវិហារសន្តសិលា និងសន្តប៉ូល ចេង រ៉ូប៊ីត តំណាងក្រុមដែលទទួលបានជ័យលាភីលេខ១នៅក្នុងកម្មវិធីស្នាដៃម្ហូបខ្ញុំនេះបានឱ្យដឹងថា «លេខ១នេះជាកម្លាំងចិត្តខ្ញុំនៅពេលទៅផ្ទះវិញអាចជួយសម្រាលការងារឪពុកម្តាយនៅផ្ទះដោយការធ្វើម្ហូប»។

រ៉ូប៊ីត គិតថា ការធ្វើម្ហូបគឺធម្មតា ប៉ុន្តែពេលយកមកប្រកួតទើបដឹងថាវាអស្ចារ្យ «បើធ្វើស្អាតនាំឱ្យមានសុខភាពល្អមិនមានជំងឺនៅក្នុងរាងកាយ»។

គៀង ស្រីពីនក្នុងវ័យ១៦ឆ្នាំ មកពីព្រះសហគមន៍ជុំគិរីបានឱ្យដឹងថា នេះជាលើកទី៣ដែលបានចូលរួមជាមួយជំទង់របស់ភូមិភាគភ្នំពេញ ហើយក្នុងពេលនេះ នាងទទួលបានចំណេះដឹងជាច្រើនអំពី ការបរិភោគអាហារឱ្យទៀងទាត់ និងត្រូវស្គាល់ពីរបបអាហារសំខាន់ៗ ដើម្បីឱ្យរាងកាយលូតលាស់ល្អជាប្រយោជន៍សម្រាប់រាងកាយនិងខួរក្បាល ជួយឱ្យយើងរីករាយ មានទំនុកចិត្តដោយមានសុខភាពល្អ៕

# លោក វី សំណាង៖ បូជាចារ្យជាឧបករណ៍របស់ព្រះជាម្ចាស់

*អត្ថបទ៖ ចាន់ម៉ានុត*

នៅក្នុងអភិបូជាលើកដំបូងនៅព្រះវិហារសន្តីម៉ារី តួតាំង នៃមណ្ឌលសកម្មភាពមេគង្គដែលជាទីកន្លែងកំណើត លោកបូជាចារ្យ យ៉ូហាន បាទីស្ត វី សំណាង ឲ្យដឹងថា«ខ្លួនខ្ញុំលែងជាកម្មសិទ្ធខ្លួនខ្ញុំទៀតហើយ រាល់ពាក្យសម្តី កាយវិការ ដៃជើង អ្វីៗទាំងអស់ជារបស់ព្រះគ្រីស្ត។»

ក្នុងធម្មទេសនានារសៀលថ្ងៃទី២៤ ខែកញ្ញា លោកបូជាចារ្យថ្មី មានប្រសាសន៍ទៀតថា ដូច្នេះលោកជាឧបករណ៍របស់ព្រះជាម្ចាស់ ជាឧបករណ៍នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ លោកបានអធិដ្ឋានសូមឲ្យអ្វីដែលលោកធ្វើ គឺដើម្បីលើកតម្កើងព្រះគ្រីស្ត និងឱ្យគ្រីស្តបរិសមើលឃើញវត្តមានព្រះអង្គក្នុងរូបកាយរបស់គាត់ជាបូជាចារ្យដែរ។

លោកបូជាចារ្យថ្មី បានថ្វាយអភិបូជាលើកដំបូងនេះអមដោយលោកអភិបាលអូលីវីយេ ផ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងមានគ្រីស្តបរិស័ទចូលរួមច្រើនកុះករផងដែរ។

លោកបូជាចារ្យថ្មីស្នើសុំឲ្យគ្រីស្តបរិស័ទបន្តអធិដ្ឋានសម្រាប់គាត់ ដើម្បីឱ្យគាត់ក្លាយជាអំបិលសម្រាប់ពិភពលោកអស់កល្បជានិច្ច។

ជាមួយគ្នានេះលោកសំណាង បានរំលឹកដល់គ្រីស្តបរិស័ទឲ្យអធិដ្ឋានជានិច្ចទោះក្នុងកិច្ចការតូចធំក្តី គឺសូមព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺដើម្បីឱ្យយើងអាចជ្រើសរើសអ្វីមួយស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។



ក្នុងឱកាសនោះលោកអភិបាល អូលីវីយេ សូមអរគុណដល់ឪពុកម្តាយរបស់លោកបូជាចារ្យ វីសំណាង ដែលបានថៃរក្សាកូន និងអនុញ្ញាតឱ្យចូលទេវវិទ្យាល័យ ដើម្បីក្លាយជាបូជាចារ្យនៅថ្ងៃនេះ។

លោកបូជាចារ្យ យ៉ូហានបាទីស្ត វី សំណាង ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ និងត្រូវចាត់ដោយលោកអភិបាលទៅបំពេញបេសកកម្មនៅមណ្ឌលសកម្មភាពភ្នំពេញខាងជើងក្នុងខែ មករា ឆ្នាំ ២០២៤។ បច្ចុប្បន្នលោកនៅបម្រើការងារនៅព្រះវិហារ ព្រះកុមារយេស៊ូបឹងទំពុន៕

# លោកបូជាចារ្យ ថៃ រតនៈ សូមឲ្យគ្រីស្តបរិស័ទកែប្រែចិត្តគំនិតប្រចាំថ្ងៃ

*អត្ថបទ៖ កែវ កញ្ញា*

នៅក្នុងពិធីអភិបូជាលើកដំបូង នៅព្រះវិហារសន្តយ៉ូសែបផ្សារតូច នារាជធានីភ្នំពេញ លោកបូជាចារ្យ ថៃ រតនៈ ហៅប៊ុនលី ណែនាំគ្រីស្តបរិស័ទឲ្យយកចិត្តទុកដាក់កែប្រែចិត្តគំនិតប្រចាំថ្ងៃ ដោយកុំគិតថា ខ្លួនជាគ្រីស្តបរិស័ទហើយអាចរួមរស់ជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខនោះ។

ក្នុងអភិបូជាកាលពីថ្ងៃទី៣ ខែតុលា កន្លងទៅ លោកមានប្រសាសន៍ទៅកាន់ គ្រីស្តបរិស័ទចូលរួមប្រមាណជិត២០០នាក់ថា ក្នុងទំនាក់ទំនងរបស់យើងប្រចាំថ្ងៃ គឺមានមនុស្សបួនប្រភេទ។ ទី១ គឺមិនពូកែនិយាយតែពូកែធ្វើ ទី២មិនពូកែធ្វើតែពូកែនិយាយ ទី៣ពូកែធ្វើហើយក៏ពូកែនិយាយ និងទី៤មិននិយាយហើយក៏មិនធ្វើដែរ។

លោកបូជាចារ្យថ្មីបន្តថា ក្នុងថ្ងៃនេះព្រះយេស៊ូបានឲ្យយើងយកចិត្តទុកដាក់មិនត្រឹមតែពាក្យសម្តីទេ គឺសូមឲ្យធ្វើសកម្មភាពដែរ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ដើម្បីអាចរួមរស់ជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខលោកបូជាចារ្យថ្មីរូបនេះ បានបញ្ជាក់ថា យើង «ត្រូវយកចិត្តទុកដាក់កែប្រែចិត្តគំនិតរបស់យើងប្រចាំថ្ងៃ» ដោយកុំគិតថាខ្លួនយើងល្អហើយ ពូកែហើយ។





លោកពន្យល់ថា៖ «បើបងប្អូនសម្រេចចិត្តថា ស្អែកខ្ញុំអត់ធ្វើបាបទៀតទេ តែនៅតែធ្វើ ជាអ្វីដែលយើងត្រឹមតែនិយាយ ដូច្នេះសូមអនុវត្ត»។

ការកែប្រែចិត្តគំនិតអាចពឹងលើការអធិដ្ឋានសុំកម្លាំងពីព្រះជាម្ចាស់ជួយកែភាពទន់ខ្សោយរបស់យើង ហើយសូមយើងទទួលអគ្គសញ្ញានានា មានដូចជា ទទួលព្រះកាយ លើកលែងទោស និងត្រូវធ្វើអំពើល្អចៀសវៀងប្រព្រឹត្តអំពើអាក្រក់។

លោកបូជាចារ្យថៃ រតនៈ (ប៊ុនលី) បានទទួលអគ្គសញ្ញាតែងជាបូជាចារ្យកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ ពីលោកអភិបាលអូលីវីយេ ផ្មីតហាស្លេនៃភូមិភាគភ្នំពេញ។ លោកបានសម្រេចចិត្តចូលទេវវិទ្យាល័យ ក្នុង២០១៥ ហើយទទួលអគ្គសញ្ញាតែងតាំងជាឧបដ្ឋាកនាថ្ងៃទី១០ កញ្ញា ២០២២ និងបានបម្រើការងារជាឧបដ្ឋាកនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច។ ក្នុងមុខងារជាបូជាចារ្យ លោកអភិបាលបានចាត់លោកឲ្យទៅបម្រើការងារនៅព្រះសហគមន៍មណ្ឌលសកម្មភាពកំពត-កែប៕

# លោកបូជាចារ្យថ្មីរំលឹកអំពីតួនាទីជាគ្រីស្តបរិស័ទ

*អត្ថបទ៖ ចាន់ ម៉ានុត*

លោកបូចារ្យប៉ូល វិនកាន់ និងលោកបូជាចារ្យអន់តូនី ថៃរតនៈ (ប៊ុនលី) បានថ្វាយអភិបូជាលើកដំបូងរួមជាមួយលោកអភិបាល អូលីវីយេ ជ្មីតហាស្លេ នៃភូមិភាគភ្នំពេញ នៅព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយេ ចំប៉ា នៃមណ្ឌលសកម្មភាពមេគង្គ កាលពីថ្ងៃទី២៤ ខែកញ្ញា មានគ្រីស្តបរិស័ទចូលរួមយ៉ាងច្រើនកុះករ។

ប៉ូល វិនកាន់ មានប្រសាសន៍ថា «នៅថ្ងៃនេះខ្ញុំមានអំណរសប្បាយដែលបានមកភូមិស្រុកកំណើតដើម្បីថ្វាយអភិបូជាជាលើកដំបូង ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់ការត្រាស់ហៅ និងទី២អរគុណព្រះសហគមន៍ ពុកម៉ែបងប្អូនដែលតែងតែគាំទ្រតាមរយៈការអធិដ្ឋាន និងតាមមធ្យោបាយផ្សេងៗ។ នេះជាកម្លាំង នឹងជាអំណរសប្បាយសម្រាប់ខ្ញុំយ៉ាងពិតប្រាកដ»។

ក្នុងធម្មទេសនា លោកបូជាចារ្យ ប៉ូល វិន កាន់ មានប្រសាសន៍ថា យើងជាគ្រីស្តបរិស័ទ យើងបានទទួលការងារមួយពីព្រះជាម្ចាស់ដូចៗគ្នា ទោះបីយើងមានមុខងារនៅក្នុងសង្គមឬក៏មានការងារមួយក្នុងព្រះសហគមន៍ យើងទាំងអស់គ្នាធ្វើការសម្រាប់ព្រះជាម្ចាស់ និងឱ្យយើងមានចិត្តសប្បុរសដូចម្ចាស់ចំការនៅក្នុងព្រះគម្ពីរថ្ងៃនេះ។

«ដូច្នេះការងារដែលយើងធ្វើ តួនាទីដែលយើងធ្វើគឺតម្រង់ឆ្ពោះទៅរកព្រះជាម្ចាស់ណែនាំឱ្យយើងមានចិត្តល្អ ឱ្យយើងមានចិត្តមេត្តាករុណាដែរ»។ លោកបូជាចារ្យបញ្ជាក់។









លោកបន្ថែមថា«សម្រាប់ខ្ញុំ ខ្ញុំទទួលមុខងារជាបូជាចារ្យបម្រើព្រះជាម្ចាស់ ដូច្នេះខ្ញុំមិនអាចនិយាយថា ខ្ញុំពូកែ ខ្ញុំល្អជាងគេ ឬក៏ខ្ញុំចេះជាងគេ ឆ្លាតជាងគេ គឺអត់ទេដោយសារមានរឿងរ៉ាវផ្សេងៗទៀតជាច្រើនដែលខ្ញុំអត់យល់ ដែលខ្ញុំអត់ដឹងនឹងខ្ញុំក៏មិនអាចធ្វើបានដែរ ដូច្នេះខ្ញុំត្រូវការបងប្អូនទាំងអស់ចូលរួមជួយជាមួយខ្ញុំដែរ»។

លោកអន់តូនី ថៃរតនៈមានប្រសាសន៍ដែរថា ការថ្វាយអភិបូជាលើកដំបូងនេះ ជាព្រះអំណោយទានដែលព្រះជាម្ចាស់ប្រទានឲ្យលោក បានកាន់ព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ហើយនេះជាបទពិសោធន៍ថ្មីមួយ។

លោកបន្តថា«ខ្ញុំមានអំណរសប្បាយ មានចិត្តសប្បាយរីករាយយ៉ាងខ្លាំង និងសូមព្រះជាម្ចាស់ប្រទានពរដល់ប្រជារាស្ត្ររបស់ព្រះអង្គ និងសម្រាប់ខ្ញុំដែរ ដើម្បីឱ្យខ្ញុំបានបន្តបេសកកម្មរបស់ព្រះអង្គ តាមរយៈការប្រារព្ធអភិបូជាប្រចាំថ្ងៃ ជាប្រយោជន៍សម្រាប់បងប្អូនគ្រីស្តបរិស័ទទាំងអស់តាមរយៈខាងផ្លូវវិញ្ញាណ។»

ជាមួយគ្នានេះ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ស្នើសុំគ្រីស្តបរិស័ទក្នុងមណ្ឌលសកម្មភាពមេគង្គបន្តអធិដ្ឋានសម្រាប់លោកបូជាចារ្យថ្មីដើម្បីបន្តនឹងបម្រើព្រះជាម្ចាស់ បម្រើព្រះសហគមន៍អស់មួយជីវិតដែលពោរពេញដោយកម្លាំង និងអធិដ្ឋានសម្រាប់យុវជនជំនាន់ក្រោយទៀតដើម្បីចូលរួមក្នុងក្រុមអ្នកបួស។

លោកប៉ូល វិន កាន់ និងលោក អន់តូនី ថៃ រតនៈ(ប៊ុនលី) ត្រូវបានតែងតាំងជាបូជាចារ្យកាលពីថ្ងៃទី២៣ ខែកញ្ញាកន្លងទៅ។ លោកអភិបាលអូលីវីយេ បានចាត់លោកទាំងពីរឲ្យទៅបំពេញបេសកកម្ម គឺលោកអន់តូនី ថៃ រតនៈ ត្រូវទៅបំពេញបេសកម្មនៅមណ្ឌលសកម្មភាពកំពត និង លោក ប៉ូល វិនកាន់ ត្រូវទៅបំពេញបេសកម្មនៅមណ្ឌលសកម្មភាពតាកែវ៕

# លោកឪពុកប្រធាន សាលេស៊ាន ដុនបូស្កូពិភពលោក ក្លាយជាកាឌីណាល់

*អត្ថបទ៖ CSC*

សម្តេចប៉ាបហ្វ្រង់ស៊ីស្ក តែងតាំងលោកឪពុកអង់ជេល ហ្វេរណាន់ដេស អាថាម(Ángel Fernández Artime) ប្រធានក្រុមគ្រួសារសាលេស៊ានដុនបូស្កូពិភពលោក ជាកាឌីណាល់ នាព្រឹកថ្ងៃទី៣០ខែកញ្ញានេះ នៅទីធ្លា អាសនៈវិហារ សន្តសិលា នាទីក្រុងរ៉ូម។

លោកឪពុក អង់ជេល ហ្វេរណាន់ដេស អាថាម ត្រូវបានប្រកាសតែងតាំងរួមជាមួយលោកកាឌីណាល់ចំនួន២០រូបផ្សេងទៀត។ នៅថ្ងៃដដែលលោកកាឌីណាល់អង់ជេល នឹងជួបជាមួយមិត្តភក្តិសាច់ញាតិ និងក្រុមសមាជិកគ្រួសារបព្វជិតដុនបូស្កូ ដែលមានបំណងជួបសាទរលោកនៅ Lapidary Gallery of the Apostolic Palace។

នៅថ្ងៃទី១ ខែតុលា លោកថ្វាយអភិបូជាលើកដំបូងក្នុងនាមជាកាឌីណាល់នៅ the Sacred Heart Basilicaនាទីក្រុងរ៉ូម។ លោកអង់ជេល ហ្វេរណាន់ដេស អាថាមប្រសូតនៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៦០នៅប្រទេសអេស្ប៉ាញ និងលោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិកក្នុងក្រុមគ្រួសារសាលេស៊ានដុនបូស្កូ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៨៧ នៅឡេអុងប្រទេសអេស្ប៉ាញ។

លោកបានសិក្សាជំនាញទេវវិទ្យា កិច្ចការព្រះសហគមន៍(Pastoral Theology)និងបានសរសេរនិក្ខេបបទ អំពីទស្សនវិជ្ជា និងគរុកោសល្យ។ លោកធ្លាប់ធ្វើជាប្រធានណែនាំក្រុមយុវជន ជានាយកសាលា ជាសមាជិកក្រុមប្រឹក្សាថ្នាក់តំបន់ និងភូមិភាគ។ ពីឆ្នាំ២០០០-២០០៦លោកក្លាយជាប្រធានតំបន់។

ក្រោយមកក្នុងឆ្នាំ២០០៩ លោកក្លាយជាប្រធានតំបន់ភាគខាងត្បូងនៃប្រទេសអាហ្សង់ទីននៅក្នុងភូមិភាគប៊ូអេនូស អ៊ែរស៍ (Buenos Aires) ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយលោកកាឌីណាល់Jorge Mario Bergoglioដែលសព្វថ្ងៃជាសម្តេចប៉ាប ហ្វ្រង់ស៊ីស្ក។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ លោកត្រូវបានជ្រើសតាំងជាប្រធានតំបន់ថ្មីមួយនៃMediterranean Spainដែលជាក្រុមគ្រួសាបងស្រីសាលេស៊ានដុនបូស្កូ។ ហើយនៅថ្ងៃទី២៥ខែមីនាឆ្នាំ២០១៤ លោកត្រូវបានជ្រើសតាំងជាប្រធានក្រុមគ្រួសាសាលេស៊ានពិភពលោកជំនាន់ទី១០ បន្តពីលោកពុកយ៉ូហានបូស្កូជាអ្នកបង្កើតក្រុមគ្រួសារសាលេស៊ានដុនបូស្កូ៕



# ការប្រកួតដើម្បីសប្បុរសធម៌រវាងក្រុម មានពិការភាពនិងតារាល្បី

*អត្ថបទ៖ កែវ កញ្ញា*

ព្រះសហគមន៍កាតូលិក និងក្រុមបាល់ទាត់ផ្ការីកគ្រប់រដូវរបស់នាយពាក់មីបានរួមគ្នាបង្កើតកម្មវិធីប្រកួតកីឡាបាល់ទាត់ សប្បុរសធម៌មួយនៅពហុកីឡាដ្ឋាន កងយុទ្ធពលខេមរភូមិន្ទ (ស្តាតចាស់)នាល្ងាចថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០២៣។

កម្មវិធីប្រកួតនេះ ចូលរួមរវាងក្រុមបាល់ទាត់យុវជនមានពិការភាពផ្នែកគថ្លង់ និងក្រុមបាល់ទាត់ផ្ការីកគ្រប់រដូវដែលជាក្រុមបាល់ទាត់សិល្បករខ្មែរក្នុងគោលដៅលើកទឹកចិត្តអ្នកមានពិការភាព មានឱកាសជួបតារាៗ និងប្រមូលមូលនិធិខ្លះៗដើម្បីគាំទ្រដល់អ្នកមានពិការភាព។ លោកស៊ាន់ សារឿន អ្នកសម្របសម្រួលខាងក្រុមបាល់ទាត់មានពិការភាពរបស់ព្រះសហគមន៍កាតូលិក មានប្រសាសន៍នេះនាថ្ងៃទី១០ ខែតុលានេះ។

លោកសារឿនបន្តថា កីឡាករខាងគថ្លង់មានចំនួន២៦នាក់ ចំណែកអ្នកគាំទ្រដែលមានពិការភាពនិងអ្នកលើកទឹកចិត្តគាំទ្រពីខាងស្ថាប័នព្រះសហគមន៍មានសរុបចំនួនជិត៣០០នាក់ រួមទាំងមហាជនជាច្រើនកុះករចូលរួម។

ការប្រកួតកីឡានេះ ធ្វើឡើងក្រោមអធិបតីភាពឯកឧត្តមឯម ច័ន្ទមករារដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាអគ្គលេខាធិការក្រុមប្រឹក្សាសកម្មភាពជនពិការ។

លោកមានប្រសាសន៍ថា ការប្រកួតនេះ គឺជាការលើកកម្ពស់ជនមានពិការភាព ការផ្តល់សិទ្ធិសេរីភាព គ្មានការរើសអើងក្រោមដំបូលនៃសុខសន្តិភាព និងការអភិវឌ្ឍក្នុងគ្រប់វិស័យ ព្រមទាំងធ្វើបរិយាបន្នជនមានពិការភាពទៅក្នុងសង្គម ដើម្បីប្រែក្លាយសង្គមមួយមានបរិយាបន្ន។

លោកសារឿនបានឲ្យដឹងទៀតថា ដើមហេតុនៃការរៀបចំព្រឹត្តិការណ៍នេះ ដោយសារជារៀងរាល់អាទិត្យ ក្រុមបាល់ទាត់ជនមានពិការភាពផ្នែកគថ្លង់បានចូលរួមលេងជាមួយមនុស្សធម្មតា ហើយខាងលោកពាក់មី បានចាប់អារម្មណ៍និងចង់ជួយលើកទឹកចិត្តដល់ពួកគាត់ ដើម្បីបង្ហាញសមត្ថភាព និងទទួលអំណរសប្បាយផង។

អ្នកសម្របសម្រួលរូបនេះបន្ថែមថា នេះជាព្រឹត្តិការណ៍ដំបូងសម្រាប់ក្រុមកីឡាករ ហើយចុងបញ្ចប់នៃការប្រកួតនេះ ក្រុមកីឡាករជនមានពិការភាពផ្នែកគថ្លង់បានលើកពានដោយមានអំណរសប្បាយ។ «វាជាជោគជ័យមួយដ៏ល្អសម្រាប់ពួកគាត់។»

លោកឆាត់ ឡេងចាន់សុជាតិ ជាអគ្គនាយកក្រុមហ៊ុនChhat Diamond Shop និងជាអ្នកផ្តួចផ្តើមការប្រកួតនេះ បានឲ្យដឹងថា គាត់តែងតែគាំទ្រក្រុមជនពិការគថ្លង់នេះ ដោយមានការប្រកួតក្រុមតូចជាមួយគ្នារាល់សប្តាហ៍ ដើម្បីឲ្យយុវជនគថ្លង់បានចូលរួមក្នុងសង្គមកាន់តែច្រើន ហើយក៏សហការជាមួយលោកពាក់មី ដើម្បីបង្កើតព្រឹត្តិការណ៍ថ្នាក់ជាតិ។

លោកបន្ថែមថា ទិសដៅរបស់យើងសំខាន់ គឺឲ្យមហាជនដឹងថា យុវជនគថ្លង់ក៏មានសមត្ថភាពដូចមនុស្សធម្មតាដែរ ហើយត្រូវលើកតម្លៃរបស់គាត់ដោយគ្មានការរើសអើង និងដាស់តឿនស្មារតីរបស់បងប្អូនមានពិការភាព កុំឲ្យគិតថា ពួកគាត់ត្រូវបានគេបោះបង់ចោល។





«តិចឬច្រើនយើងចង់ឲ្យសប្បុរសជនដទៃទៀតចាប់ផ្តើមងាកមកជួយគ្នា ជាហិរញ្ញវត្ថុក្តី ជាអាហារក្តី ជាសម្ភារក្តី ទៅអង្គការដែលកំពុងត្រូវការជំនួយដើម្បីបន្តនិរន្តរភាពការផ្តល់សេវាកម្មថែទាំដល់ជនមានពិការភាព។» លោកសុជាតិបន្ថែម។

លោកថែម ចាន់រ៉ា ហៅនាយពាក់មី ជាតារាកំប្លែង និងជាប្រធានក្រុមបាល់ទាត់ផ្ការីកគ្រប់រដូវ ឲ្យដឹងថា លោកចង់ចូលរួមលើកទឹកចិត្តដល់បងប្អូនមានពិការភាពឲ្យចេះតស៊ូក្នុងជីវិត ហើយចង់ឲ្យពួកគាត់បញ្ចេញសមត្ថភាពឲ្យអ្នកដទៃឃើញថា គាត់ពិការមែនតែគាត់អាចធ្វើអ្វីដូចមនុស្សធម្មតា។

លោកពាក់មី បន្ថែមថា វាជាឱកាសមួយអាចឲ្យក្រុមមានពិការភាព លេងជាមួយតារាល្បីៗដែលជាIdle លេងក្នុងតារាងធំ មានអ្នកមើលច្រើនតាមការផ្សាយផ្ទាល់តាមបណ្តាញសង្គមដែលធ្វើឲ្យពួកគាត់មានមោទនភាព។

«ជាលទ្ធផល យើងឃើញស្នាមញញឹមរបស់ពួកគាត់មែន ជាពិសេសគាត់បានប្រកួតឈ្នះ ហើយលើកពាន។ គាត់ដេកឱបពាន គាត់យំ គាត់សប្បាយ គាត់រំភើប ជាអ្វីដែលក្រុមការងារយើងខ្ញុំចង់បាន។» លោកពាក់មីបញ្ជាក់។

ជាមួយគ្នានេះ ក្រុមផ្ការីកគ្រប់រដូវរបស់លោកក៏នឹងមានគម្រោងរៀបចំការប្រកួតជាមួយក្រុមជនពិការភ្នែក នៅពាក់កណ្តាលខែវិច្ឆិកាខាងមុខនេះ ដើម្បីលើកកម្ពស់ជនពិការភ្នែក និងចង់ទទួលបទពិសោធន៍អំពីភាពងងឹតនិងការពិបាកការតស៊ូរបស់ជនពិការភ្នែក។

តាមលោកសារឿនបានឲ្យដឹងថា ថវិកាដែលប្រមូលបានគឺប្រមាណ៤៥០០ដុល្លារអាមេរិកដែលបានមកពីសប្បុរសជនក្នុងប្រទេស ដើម្បីចាត់ចែងក្នុងព្រឹត្តិការណ៍ប្រកួត ហើយសល់ពីនោះនឹងបែងចែកទៅតាមស្ថាប័នដែលកំពុងថែទាំជនមានពិការភាពនានា៕








# សម្ដេចប៉ាបទំនាក់ទំនងទៅក្រុមបព្វជិតព្រះសហគមន៍នៅហ្គាហ្សា



ស្របពេលដែលអំពើហិង្សា និងការផ្ទុះអាវុធនៅតែបន្តនៅតំបន់ហ្គាហ្សាសម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ បានដានដានសភាពការណ៍នៅទីនោះដោយប្រុងប្រយ័ត្ន។

វ៉ាទីកង់ញូវបានរាយការណ៍ថា ដើម្បីជានាសន្តិសុខនិងសុវត្ថិភាព ក៏ដូចជាសេរីភាពនៃជំនឿ នៅដែនដីពិសិដ្ឋ សម្ដេចប៉ាប តែងតែទំនាក់ទំនងតាមទូរសព្ទជាបន្តបន្ទាប់ទៅកាន់អ្នកទទួលខុសត្រូវព្រះសហគមន៍នៅក្នុងតំបន់ហ្គាហ្សា ដើម្បីដឹងអោយប្រាកដអំពីស្ថានភាព ព្រះសហគមន៍នៅទីនោះ។

នៅក្នុងពេលសន្ទនា សម្ដេចប៉ាបតែងតែបញ្ជាក់ថា គ្រីស្ដបរិស័ទ និងទ្រង់តែតែបន្តអធិដ្ឋានជូនអស់ជនដែលរងគ្រោះ និងទូលអង្វរសុំសន្តិភាព។

បងស្រីណាបេឡាសេឡេស (Nabila Saleh) សមាជិកព្រះសហគមន៍កាតូលិក នៅជេរូសាឡឹម បានចែករំលែកថា នេះគឺជាកិត្តិយសណាស់ដែលបងស្រីអាចមានឱកាសសន្ទនាជាមួយនឹងសម្ដេចប៉ាបដោយផ្ទាល់ បន្ទាប់ពីទ្រង់បានទំនាក់ទំនងទៅលោកឪពុកអ្នកទទួលខុសត្រូវ។

បងស្រីបានបន្តថា នៅក្នុងអំឡុងពេលសន្ទនា ទ្រង់សួរសុខទុក្ខយើង ទ្រង់ចង់ដឹងអំពីសភាពការណ៍នៅក្នុងព្រះសហគមន៍ ខណៈដែលព្រះសហគមន៍យើងកំពុងតែជួយសង្គ្រោះអ្នកជំងឺ កុមារ គ្រួសារទុរគតជន ប្រមាណជា ៥០០ នាក់៕

# សន្តអាសនៈស្វាគមន៍ការដោះលែងលោកបូជាចារ្យ១២នាក់នៅប្រទេសនីការ៉ាហ្គ័រ



សន្តអាសនៈបានប្រកាសស្វាគមន៍ចំពោះការសម្រេចចិត្តធ្វើការដោះលែងលោកបូជាចារ្យ១២ រូប ពីពន្ធនាគារនៅក្នុងប្រទេសនីការ៉ាហ្គ័រកាលពីពេលថ្មីៗនេះ។

លោក ម៉ាតេអូ ប្រ៊ុននី (Matteo Bruni) ប្រធានការិយាល័យព័ត៌មានសន្តអសនៈបានប្រកាសថា លោកអាចបញ្ជាក់បានថា សន្តអសនៈបានស្នើសុំទទួលលោកបូជាចារ្យ១២ នាក់មកពីប្រទេសនីការ៉ាហ្គ័រ ដែលទើបតែត្រូវបានដោះលែងនៅក្នុងប្រទេសនេះ។

លោកបានអះអាងថា លោកបូជាចារ្យទាំង១២ រូប គឺនឹងត្រូវទទួលមកបម្រើការនៅក្នុងព្រះសហគមន៍នៅទីក្រុងរ៉ូមក្រោយពេលដែលពួកគេបានត្រូវអាជ្ញាធរនៅក្នុងប្រទេសនោះ បានដោះលែង។

លោកបូជាចារ្យទាំង១២ រូប ត្រូវបានគេដឹងថា បានរងនូវបទចោទប្រកាសមួយចំនួន នៅក្នុងប្រទេសនេះ ខណៈដែលទំនាក់ទំនងការទូតរវាងសន្តអាសនៈ និងនីការ៉ាហ្គ័រកំពុងតែរង្គោះរង្គើ ជុំវិញអំពីផ្ដាច់ការនៅក្នុងរដ្ឋមួយនេះ៕

# អឺរ៉ុប និងអាមេរិកកំពុងស្វែងរកកិច្ចសហប្រតិបត្តិការសាកលដើម្បីឆ្លើយតបនឹងវិបត្តិផ្សេងៗ

មេដឹកនាំអាមេរិក និង សហភាពអឺរ៉ុប កំពុងតែស្វះស្វែងរកកិច្ចសហប្រតិបត្តិការជាសាកល មួយដើម្បីឆ្លើយតបនឹងវិបត្តិសាកលនានា ។

តាមសេចក្ដីរាយការណ៍បានឲ្យដឹងថា មេដឹកនាំអាមេរិក និង អឺរ៉ុប បានជួបគ្នាកាលពីចុងសប្ដាហ៍មុន ដើម្បីបង្ហាញពីការប្ដេជ្ញាចិត្តរបស់ពួកគេនៅក្នុងការស្វែងរកដំណោះស្រាយឆ្លើយតបនឹង បញ្ហានៅដែនដីពិសិដ្ឋ និងនៅអ៊ុយក្រែន។

ប្រភពដដែលបានបន្តថាលោកចូបៃដិន ប្រធានាធិបតីអាមេរិក បានបើកទ្វារទទួល លោក ឆាល់ មីសែល (Charles Michel) ប្រធានក្រុមប្រឹក្សាអឺរ៉ុប និង លោកស្រី យូស៊ូឡា វុន ឌ័រ ឡេយេន ប្រធានគណកម្មការអឺរ៉ុប ដើម្បីពិភាក្សាគ្នាស្វែងរកទស្សនៈនិងកិច្ចសហប្រតិបត្តិការនៅក្នុងការបង្ការនិងឆ្លើយតបនឹងវិបត្តិនានា នៅលើពិភពលោក ជាពិសេសគឺបញ្ហាដែលអូសបន្លាយនៅអ៊ុយក្រែន និង ទំនាស់ថ្មីៗរវាអ៊ីស្រាអែល និង ហាម៉ាស់ នៅហ្គាហ្សា ។

ពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងនេះ លោកស្រី យូស៊ូឡា វុន ឌ័រ ឡេយេន បានកំពុងតែរងការរិះគន់ពីប្រទេសសមាជិកសហភាពអឺរ៉ុប ដោយលើកឡើងថា ការខិតខំរបស់លោកស្រី គឺហាក់ដូចជាដើរលើសពីព្រំដែននៃការទទួលខុសត្រូវរបស់លោកស្រី ដែលតំណាងអោយផលប្រយោជន៍របស់ប្លុក៕

## ប្រជាជនកាតូលិកកើន តែចំនួនបព្វជិតធ្លាក់ចុះ



ទីភ្នាក់ងារព័ត៌មានហ្វីដេស (Fides) បានរាយការណ៍ថា ចំនួនប្រជាជនដែលមានជំនឿនៅលើ គោលលទ្ធិកាតូលិកមានកំណើនកើនឡើង ប៉ុន្តែបានកត់សំគាល់ថាចំនួនបុព្វជិត ជាពិសេសគឺបូជាចារ្យគឺមានការថយចុះ ។

ប្រភពដដែលបានរាយការណ៍ថា ចំនួនប្រជាពលរដ្ឋដែលមានជំនឿនៅលើគោលលទ្ធិរបស់ ព្រះសហគមន៍កាតូលិក សរុបគឺមានដល់ទៅ ១.៣៧៥ ពាន់លាននាក់ ពោលគឺមានកំណើន កើនឡើងប្រមាណជា ១៦,២៤ លាននាក់ ឬកើនឡើងប្រមាណជា ១៧,៦៧ ភាគរយ។

ប្រភពដដែលបានបន្តថា តួលេខនេះ ត្រូវបានគេដឹងថា ប្រមូលចងក្រងគិតត្រឹម ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១ រីឯកំណើននេះវិញគឺធៀបនឹងតួលេខ ដែលបានចងក្រងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ។

ប្រភពដដែលបានបន្តថា កំណើននេះ គឺឃើញមានកត់ត្រា នៅគ្រប់ទ្វី លើកលែងទ្វីបអឺរ៉ុប ហើយកន្លែងដែលកំណើនខ្លាំងគឺនៅអាហ្វ្រិក និង នៅទ្វីបអាមេរិក ។

ដោយឡែកចំនួនលោកអភិបាល និង លោកបូជាចារ្យគឺមានការធ្លាក់ចុះគួរឲ្យកត់សំគាល់ដែលនៅក្នុងនោះ គឺមាន លោកអភិបាលសរុប ៥.៣៤០ រូប លោកបូជាចារ្យមានសរុប ៤០៧.៨៧២ នាក់ ធ្លាក់ចុះ ២.៣៤៧ នាក់ ដោយឡែកបងស្រីវិញ គឺមានចំនួនតិចជាង ១០.៥៨៨ នាក់៕

## ជំនួបកំពូលសន្តិភាពនៅទីក្រុងកៃរ៉ូមិនមានកុងសង់ស៊ីស

មេដឹកនាំពិភពលោកបានជួបប្រជុំគ្នានៅក្នុងទីក្រុងកៃរ៉ូ ប្រទេសអេស៊ីប ដើម្បីបន្ធូកំដៅនៃអំពើហិង្សានៅតំបន់ហ្គាហ្សា ប៉ុន្តែកិច្ចប្រជុំកំពូលនេះបានបញ្ចប់ដោយមិនមានកុងសង់ស៊ីសឡើយ។

មេដឹកនាំអារ៉ាប់ និងអឺរ៉ុប បានជួបប្រជុំគ្នានៅកៃរ៉ូ ដើម្បីពិភាក្សាអំពីវិបត្តិនៅតំបន់ហ្គាហ្សា ប៉ុន្តែអ្នកដើរតួនាទីសំខាន់នៅក្នុងជម្លោះដូចជាអ៊ីរ៉ង់ និង អ៊ីស្រាអែល មិនបានចូលរួមនៅក្នុងកិច្ចប្រជុំកំពូលនេះនៅឡើយទេ។

ប៉ុន្មានម៉ោងបន្ទាប់ពីកិច្ចពិភាក្សាបានចាប់ផ្ដើមអ្នកចូលរួមនៅតែបែកបាក់គ្នាយ៉ាងខ្លាំង។ នៅចុងបញ្ចប់នៃកិច្ចប្រជុំកំពូលគឺគ្មានសេចក្ដីប្រកាសឬសេចក្ដីថ្លែងការណ៍ណាមួយត្រូវបានចេញផ្សាយឡើយ។

ទន្ទឹមនឹងនេះដែរអ៊ីស្រាអែលបានបង្កើនការទម្លាក់គ្រាប់បែករបស់ខ្លួននៅតំបន់ហ្គាហ្សា មុនការវាយលុកតាមផ្លូវគោក ដែលអាចកើតមាន។

យោងតាមក្រុមហាម៉ាសមនុស្សជាង ២៦០ នាក់ត្រូវបានសម្លាប់ក្នុងរយៈពេល ២៤ ម៉ោង។ កាលពីថ្ងៃសៅរ៍ក្រុមហ៊ុនដឹកជំនួយដំបូងត្រូវបានអនុញ្ញាតឱ្យឆ្លងចូលតំបន់ហ្គាហ្សាពីប្រទេសអេហ្ស៊ីបដោយផ្ដល់អាហារទឹកនិងការផ្គត់ផ្គង់វេជ្ជសាស្ត្រ។

នៅកន្លែងផ្សេងទៀតភាពតានតឹងកំពុងកើនឡើងនៅតាមព្រំដែនខាងជើងរបស់អ៊ីស្រាអែលជាមួយប្រទេសលីបង់។ ប្រជាជនអ៊ីស្រាអែលរស់នៅក្នុងសហគមន៍ចំនួន ១៤ នៅជិតជួរមុខកំពុងត្រូវបានជម្លៀសចេញ៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ




## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង



## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម







